# កន្ទេលក្រហម

***ខ្មែរ***បុរាណទទួលភ្ញៀវដោយអង្គុយរាបស្មើលើរនាប ឬក្តារក្រាលនៃលំនៅដ្ឋាន ។ ប្រសិនបើអង្គុយលេងនៅក្រោមផ្ទះ ច្រើនលើគ្រែរនាប ។ ពេលនោះគេតែងរាក់ទាក់បណ្តើរនិងយកកន្ទេលមកក្រាលបណ្តើរពីលើក្តារក្រាលឬរនាបនោះ ។ ប្រសិនបើជាប់មាត់ មិនអាចដើរទៅយកកន្ទេលបាន គេតែងប្រកូកហៅកូនចៅថា «យកកន្ទេលក្រហមមកក្រាល ! យកទឹកតែទឹកក្តៅមក !...»។ នោះបានន័យថាគេទទួលស្គាល់ភ្ញៀវដោយក្តីគោរពនិងរាប់អានបំផុត ។ ការទទួលភ្ញៀវនៅផ្ទះនៃអ្នកទីក្រុង ច្រើនប្រើកៅអីសាឡុង ។ តែអ្នកនៅជនបទភាគច្រើនណាស់ ដែលនៅតែប្រើកន្ទេលដដែល ពិសេសកន្ទេលក្រហម ។

កន្ទេលខ្មែរមានច្រើនប្រភេទ ដូចជាកន្ទេលត្បាញពី : ស្លឹកត្នោត រំចេក ចចូត រុន ផ្តៅ កក់មូល កក់ជ្រុង...។ ចំពោះកន្ទេលទាំងអស់នោះ មាននាទីបំរើដោយឡែកៗពីគ្នា ។ ដូចជាកន្ទេលស្លឹកត្នោតឬស្លឹករំចេក សំរាប់ក្រាលហាលស្រូវ ។ កន្ទេលកក់ជ្រុងសំរាប់ក្រាលបរិភោគបាយក្នុងគ្រួសារមានកូនតូចៗ ដែលច្រើនធ្វើឱ្យជ្រុះបាយឬកំពប់សម្លរជាដើម ។ ចំពោះកន្ទេលក្រហមត្បាញពីកក់មូល ដែលគេរាប់ថាជាត្រីមុខនោះ ច្រើនក្រាលទទួលភ្ញៀវសំរាកឬពិសាបាយ ។ ដើម្បីធានាកុំឱ្យកន្ទេលនោះប្រឡាក់ ម្ហូបដែលលើកមកទទួលភ្ញៀវ គេច្រើនដាក់ក្នុងថាសឬដាក់ះលើតុឈើ ដែលមានកំពស់ប្រមាណពាតឹក ។ បច្ចុប្បន្ននេះ គេច្រើនរៀបតុទាបនោះសំរាប់



តែព្រះសង្ឃឆាន់នៅក្នុងវត្ត ។



*តម្បាញកន្ទេលក្រហម*

*(ដកស្រង់ចេញពីសៀវភៅរឿងព្រេងខ្មែរដោយរូបភាពសំរាប់កុមារលេខ៨០)*

កន្ទេលកក់មូលនោះខ្មែរនិយមហៅថាកន្ទេលក្រហម ព្រោះគេនិយមត្បាញពណ៌ក្រហមជាមួយពណ៌ដទៃទៀត ។ ម៉្យាងទៀតជាយដែលចំ ដើម្បីធានាឱ្យជាប់រឹមនោះ គេច្រើនប្រើកំណាត់ជាតិពណ៌ក្រហមទៀត ។ របរ

ត្បាញកន្ទេលក្រហម គឺជាជំនាញប្រពៃណីទំនៀមទំលាប់ចេះបន្តពីដូនតា ។ ជំនាញនេះមិនមានភាពស្មុគស្មាញ ប្រើឧបករណ៍ទំនើបឡើយ ។ ការផលិតច្រើនមានលក្ខណៈជាគ្រួសារនៃកសិករ ដែលត្បាញនៅពេលទំនេរ ក្រោយការប្រមូលផលស្រែចំការ ។ នៅពេលត្បាញគេប្រើកំលាំងតែពីរនាក់ប៉ុណ្ណោះ ពិសេសកំលាំងស្ត្រី ។ ម្នាក់ជាអ្នកកាន់ធ្មេញឈើត្បាញ និងម្នាក់ទៀតកាន់ឈើតូចវែង ចាំចាក់ចំរៀកកក់ឱ្យចូលទៅក្នុងខ្សែក្រចៅ ។ ឯអ្នកកាន់ឈើធ្មេញត្បាញ ចាំតែដំចំរៀកកក់ដែលគេចាក់នោះឱ្យកើតជាសាច់កន្ទេល ។ ចំណែកឯបុរស ជំនួយលើកកក់ដែលនៅស្រស់មានទំងន់ឬវេញក្រចៅឱ្យជាប់គ្នាកើតជាខ្សែ ។

វត្ថុធាតុដើមសំរាប់ផលិតកន្ទេលក្រហមមាន : ក្រចៅ កក់មូល និងល័ខ ។

<u>**ក្រចៅ**</u> : ជាតិណជាតិម៉្យាង មានស្លឹកពណ៌បៃតងខ្ចីរាងទ្រវែងហើយចុងស្រួច ប្រវែងពី៥ទៅ១០សង្ទីម៉ែត្រ ។ ដើមមានកំពស់ពី១,៥ម៉ែត្រទៅ២ម៉ែត្រ ដោយមានវិជ្ឈមាត្រពី១ទៅ២សង្ទីម៉ែត្រ ។ គេដាំវាដើម្បីយកសរសៃធ្វើជាខ្សែថង់ឬបាវ ។គេប្រមូលផលក្រចៅនៅពេលវាចេញផ្កាដំបូងឬមានផ្លែខ្លះ។ ដោយពុំទុកដល់ពេលវាទុំឡើយ ។ គេកាប់ដើមវាត្រឹមគល់ ហើយកាត់ចុងចោល ។ គេបកសំបកវារួចចងទុកជាបាច់ៗ ។ បន្ទាប់មកយកវាទៅត្រាំទឹកពី១០ទៅ១២ថ្ងៃ ទើបស្រង់យកទៅលាងទឹកថ្លាស្អាត ហើយយកទៅហាលថ្ងៃ ។ ក្រោយមកគេវេញវាឱ្យកើតជាខ្សែវែងជាប់គ្នា ហើយមូរជាវប៉ុំដូចអំបោះហុង ។





ដើមក្រចៅ (ដកស្រង់ចេញពីសៀវភៅរឿងព្រេងខ្មែរដោយរូបភាពសំរាប់កុមារលេខ៨០)

<u>**កក់មូល**</u> :

អ្នកត្បាញកន្ទេល មិនមែនសុទ្ធតែជាអ្នកដាំកក់ទេ ។ គេដាំកក់ដោយព្រោះគ្រាប់មានទំរង់តូចល្អិតដូចជាផ្លែស្មៅពន្លើយ ។ គេដកយកទៅស្ទូង

ដូចស្នូងស្រូវប្រដេញទឹកតាមមាត់បឹងឬមាត់ទន្លេ គឺទឹកស្រកត្រឹមណាគេស្ទូងត្រឹមនោះ ។ កក់ជាប្រភេទស្មៅម្យ៉ាង មានស្លឹកវែង ស្រដៀងនឹងស្លឹកស្រូវ



*ដើមកក់ (ដកស្រង់ចេញពីសៀវភៅរឿងព្រេងខ្មែរដោយរូបភាពសំរាប់កុមារលេខ៨០)*

មានកំពស់ពី០,៨០ម៉ែត្រទៅ១,៥០ម៉ែត្រ ។ ការប្រមូលផលកក់ គេជ្រើសរើសយកតែដើមធំថ្លោសៗ ព្រោះងាយស្រួលច្រៀកជាចំរៀកតូចៗ ដោយហូតយកបណ្តូលចេញ ។ បន្ទាប់មកទើបយកទៅហាលថ្ងៃឱ្យស្ងួត រួចចង



ជាចាច់ទុកនៅក្នុងផ្ទះ ។

- **ល័ខ** :

សម័យបុរាណគេផលិតល័ខពីធម្មជាតិ ។ ដូចជាពណ៌លឿងគេយកពីដើមរមៀត ពណ៌ក្រហមយកចេញពីសំបកស្បែងជាដើម ។ តែបច្ចុប្បន្ននេះ គេមានល័ខដែលផលិតដោយសារធាតុគីមី មានប្រាំពណ៌គឺ ពណ៌ស្វាយ ក្រហម លឿង បៃតងនិងអាចម៍ដែក ។ ចំពោះកក់ដែលជ្រលក់ល័ខរួចហើយ ត្រូវយកទៅហាលថ្ងៃឱ្យស្ងួត ដោយប្រើរយៈពេល២ឬ៣ថ្ងៃ យោលទៅតាមធាតុអាកាស ។ គេឧស្សាហ៍ប្រែត្រឡប់ចុះឡើងដើម្បីឱ្យស្ងួតល្អនិងសព្វសាច់។ ប្រសិនបើនៅសើមអាចបណ្តាលឱ្យកន្ទេលធាប់ពុកផុយ។

ទោះបីជាបច្ចុប្បន្ននេះ មានការនាំចូលកន្ទេលជ័រពីបរទេសក៏ដោយ ក៏ការផលិតកន្ទេលក្រហមខ្មែរ ពុំមានការថយចុះដែរ ។ ព្រោះកន្ទេលជ័រគេច្រើនប្រើក្នុងជីវភាពធម្មតា ។ មិនតែប៉ុណ្ណោះកន្ទេលក្រហមខ្មែរ បាននាំចេញទៅលក់នៅបរទេសទៀត ដូចជា : ប្រទេសវៀតណាម ថៃ ឡាវ ជប៉ុន កូរ៉េខាងត្បូង និងបណ្តាប្រទេសនៅអឺរ៉ុបខ្លះដែរ ។

ជំនាញនេះ ច្រើនផលិតនៅស្រុកកំពង់ត្រឡាចនៃខេត្តកំពង់ឆ្នាំង និងនៅក្នុងខេត្តកណ្តាលនៃស្រុកខ្សាច់កណ្តាល ស្រុកល្វាឯមឋិតនៅតាមដងទន្លេ ដែលជាភាពងាយស្រួលដឹកជញ្ជូនយកមកកាន់ទីប្រជុំជន តាមផ្លូវទឹកឬតាមផ្លូវគោកក៏បាន ។ មុខរបរនេះមិនមានប្រើដើមទុនច្រើនទេ តែប្រើពេលវេលាយូរ នឿយហត់ ដែប្រឡាក់ល័ខមើលទៅគួរឱ្យចាប់អារម្មណ៍ពីភាពមិនស្អាត.... តែទទួលកម្រៃតិចតួច ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ក៏ប្រជារាស្ត្រនៃតំបន់នេះ នៅតែតស៊ូបន្តមរតកពីដូនតាផ្តល់ឱ្យជារៀងរហូត។

# កំណាត់[១] នៅប្រទេសកម្ពុជា

***ចម្លាក់***តាមប្រាសាទនានា យើងឃើញនាងទេពអប្សររាប់ពាន់ ស្លៀកកំណាត់សំពត់លាត មានផ្កា ក្រាស ស្តើង ឬផ្ទនជីបភ្លឺ ដូចជានៅប្រាសាទភ្នំបាក់ខែង ។ ភ្លឺនោះមានលក្ខណៈល្អិតរមេញជាប់ល្អ គួរឱ្យចាប់អារម្មណ៍ដូចសម័យវិទ្យាសាស្ត្រគ្រាឥឡូវនេះដែរនោះ មានដូចជានៅប្រាសាទលលៃ និងប្រាសាទធម្មានន្ទជាដើម ។ តែចម្លាក់ថ្មនោះ មិនអាចបញ្ជាក់ឱ្យយើងកំណត់ថាផលិតពីអ្វី ។

តាមកំណត់ហេតុលោកជីវតាក្វាន់ ដែលមកស្រុកខ្មែរនៅឆ្នាំ១២៩៦បានរៀបរាប់ថា : ការចិញ្ចឹមដង្កូវនាង បានកើតមានចាប់ពីស.វទី១៣។ ពាក្យសូត្រនេះមានចារលើសិលាចារឹក K.347 ស.វទី១០ Phañ sutra 1 : សំលៀកបំពាក់ឬកំណាត់សំរាប់បិទបាំងរាងកាយធ្វើពីសូត្រ ។

សិលាចារឹក K.4៥៩ ចារនាស.វទី១០នៅប្រាសាទភិមានអាកាសមានឃ្លាមួយ : ....កំណាត់សូត្រពណ៌ស្រស់មកពីប្រទេសចិន....។ យោជតាមសិលាចារឹកដែល បានចាររៀបរាប់ពីគ្រឿងបូជាសំរាប់ប្រាសាទខ្លះ។ ដូចជា :

១-បច្ចុប្បន្ន ខ្មែរនិយមសរសេរពាក្យក្រណាត់ ដែលគ្មានក្នុងវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជជួនណាត ។ ពនជាលោកសរសេរ«កំណាត់» ព្រោះយោលលើការប្រើប្រាស់កាត់ជាកំណាត់ៗ ។ លោកមានព្រះបន្ទូលពន្យល់ក្នុងអំឡុងទសវត្ស ១៩៦០ តាមវិទ្យុជាតិ ។





*ការស្ងោរសំបុកដង្កូវនាង ដើម្បីយកសរសៃសូត្រ*
*(ដកស្រង់ចេញពីទស្សនាវដ្តីចាំរ៉ានី ខែ May 2006 ទំព័រ 60)*

-**ប្រាសាទតាព្រហ្ម** : «....ក្នុង១ឆ្នាំ គេត្រូវប្រើសំលៀកបំពាក់ ៤០០៩៥ សំរាប់បំឡាស់ គំនរសំពត់មកពីស្រុកចិន៩៦៧ កំណាត់សូត្រ ៥១២គី.....» ។

-**ប្រាសាទព្រះខាន់** : «....ប្រើប្រាស់ក្នុង១ឆ្នាំនូវសំលៀកបំពាក់ផ្សេងៗទៀតសំរាប់អទិទេព៣៧១២សំរាប់ គ្រែដេក១១៣ មុងធ្វើពីសូត្រប្រទេសចិន៣២៣....។»

សេចក្តីនេះបញ្ជាក់ថា ខ្មែរបានប្រើសូត្រតាំងពីសម័យមុនស.វទី១៣នៃគ្រិស្តសករាជ ដោយបាននាំចូលពីបរទេស ។ តែយើងអាចដឹងថា ខ្មែរចេះត្បាញតាំងពីសម័យបុរេប្រវត្តិសាស្ត្រ គឺយោលតាមអ្នកប្រាជ្ញបុរាណវិទ្យាបានរកឃើញសំណល់ក្បាលត្រល់នៅម្លូរព្រៃក្នុងខេត្តព្រះវិហារ ។ ស្ថានីយ៍នេះមានអាយុ២០០ឆ្នាំមុនគ្រិស្តសករាជ ។ ប៉ុន្តែវត្ថុធាតុដើមដែលគេយកមកត្បាញជាកំណាត់ ពិសេសពាក្យសូត្រទើបតែមាននៅក្នុងសម័យអង្គរ ។



*ផលិតផលពីសូត្រ*

*(ដកស្រង់ចេញពីទស្សនាវដ្ដីតារ៉ានី ខែ May 2006 ទំព័រ 60)*

លោក George Groslier បានពន្យល់បន្ថែមពីការសរសេររបស់ចិនស្ដីពីការត្បាញនៅស្រុកខ្មែរនាឆ្នាំ២០២-២២០មុនគ្រឹស្តសករាជថា «នៅក្នុងព្រះរាជាណាចក្រនេះ គេមិនចិញ្ចឹមដង្កូវនាងនិងមិនដាំដើមធ្មៃទេ តែគេផលិតកំណាត់អំពីកប្បាស» ។ យើងក៏មិនអាចដឹងថាមានកំណាត់ផលិតពីធ្មៃដែរ តែគេបានឃើញសិលាចារឹក K.726 ស,វទី៧ បានចារពីពាក្យធ្មៃ = dami ក្លាយមកពីភាសាម៉ាឡេថា < rami >។ travan dami =ត្រពាំងធ្មៃ ជាទីកន្លែងមួយក្នុងសិលាចារឹកទឹកឆា ។ អ្នកកត់ត្រាចិននៅស,វទី១៣ ក៏បានបញ្ជាក់ផងដែរថា «សូម្បីតែអ្នករស់នៅព្រៃភ្នំ ក៏ចេះត្បាញសំពត់ស្លៀកដែរ តែសាច់កំណាត់គគ្រើមគគ្រើម ហើយមានក្បាច់ក្រវេមក្រវាម ។ ឯអ្នកស្រុកដែលប្រើសំឡីកប្បាស មិនទាន់ចេះរវៃអំបោះដោយប្រើរហាត់ទេ គឺគេប្រើដៃត្រកួញអំបោះយកមកត្បាញ ។ ចំពោះបច្ចេកទេសត្បាញ គេចងចុងម្ខាងជាប់នឹងចង្កេះ រួចចុងម្ខាងទៀតគេចងភ្ជាប់នឹងចង្អូច ទើបចាប់ផ្ដើមត្បាញ...» ។ វិធីរបៀបនេះនាងខ្ញុំបានប្រទះឃើញបងប្អូនស្ត្រីខ្មែរលើ នៅ





*ចម្លាក់នាងទេពអប្សរស្លៀកកំណាត់សំពត់នៅតាមប្រាសាទនានា*

*(ដកស្រង់ចេញពីទស្សនាវដ្ដីតារ៉ានី ខែ May 2006 ទំព័រ 60)*

ខេត្តរតនៈគីរីនិងខេត្តមណ្ឌលគីរី កំពុងត្បាញក្នុងគ្រាបច្ចុប្បន្ន ហើយក៏មិនទាន់មានប្រើរហាត់រវៃដែរ គឺគេយកអំបោះមកមូរហើយយកមកត្បាញ ។ គេបោះត្រល់ចុះឡើងចេញជាខ្នាតក្ដួយឬសំពត់ប៉ឹងសំរាប់បុរស និងសំពត់សំរាប់នារីគ្រប់ពណ៌ជាបន្ទះៗ រួចហើយទើបដេរភ្ជាប់ៗគ្នា ។

ចំពោះប្រវត្តិនៃការរកឃើញវិធីផលិតសូត្រ យើងខ្ញុំឃើញមានឯកសារមួយបញ្ជាក់ថា : គ,ស៥០០ ដោយមានការខ្នះខ្នែងពីព្រះចៅអធិរាជនិងព្រះអង្គម្ចាស់នៃប្រទេសនានា ទើបមានការចិញ្ចឹមដង្កូវនាង ហើយបែកខ្ចរ

ខ្វាយចូលដល់ប្រទេសជប៉ុន ។ គ.ស៦០០ បានសាយចូលដល់ទ្វីបអឺរុប ហើយចូលដល់ប្រទេសបារាំងក្នុងគ.ស៨០០ ។

ចំណែកប្រទេសខ្មែរបេះចិញ្ចឹមដង្កូវនាងស្ទើរតែក្រោយគេ ថ្វីត្បិតតែប្រទេសខ្មែរនិងប្រទេសចិននៅមិនសូវឆ្ងាយពីគ្នា ហើយមានទំនាក់ទំនងមិត្តភាពជាមួយគ្នាជាយូរណាស់មកហើយ ។ ប៉ុន្តែនៅឆ្នាំ១៩៥០ ការចិញ្ចឹមនាងបានចុះយ៉ាងខ្លាំង ព្រោះខ្មែរភាគច្រើនបានប្រតិបត្តិតាមធម៌ព្រះពុទ្ធ «បាណាតិបាតា» មិនឱ្យសម្លាប់ភាវៈរស់ ដែលមានការស្ងោរដង្កូវនាងដើម្បីយកសូត្រ ។ នៅអំឡុងទសវត្សនេះដែរ ខ្មែរនៅតែនិយមប្រើសំពត់សូត្រ តែនាងខ្ញុំតែងឃើញមានការដឹកជញ្ជូនកំណាត់សូត្រពណ៌សទាំងកី។ យកមកជ្រលក់ផ្លែម៉ឃ្លឿឱ្យមានពណ៌ខ្មៅ មានលក្ខណៈទ្រង់ទ្រាយជាសិប្បកម្ម ប្រើបច្ចេកទេសជំនឹងញញួរឈើដោយកម្លាំងពួកបុរស ដើម្បីបញ្ជាន់ឱ្យចូលពណ៌ជាប់ល្អ ដើម្បីបំរើតម្រូវការស្ត្រីខ្មែរចាស់ៗ[១] និយមស្លៀក គេហៅថា«កំណាត់សំពត់មុយអាសៀងហៃ» ។ ម្យ៉ាងទៀតស្ត្រីខ្មែរជំនាន់នោះដែលជាមន្ត្រីរាជការធ្វើការនៅការិយាល័យ ពិសេសអ្នកគ្រូបង្រៀននិយមស្លៀកសំពត់សូត្រមាន : ហូល អន្លូញ(លាតឬជរជើង) ផាមួង (កន្លក់ លាព ជរជើង) ។ ឯបុរសនៅផ្ទះនិយមស្លៀកសារុងសូត្រ រហូតដល់ឆ្នាំ១៩៧០ទើបអាក់ខាន ។ បញ្ហានេះគឺដោយសារសង្គ្រាម ដែលរដ្ឋាភិបាលឱ្យអ្នករដ្ឋការស្លៀកពាក់របៀបអ្នកប្រយុទ្ធឬអ្នកការពារសន្តិសុខ ។

បច្ចុប្បន្នមានតំបន់មួយ គឺនៅស្រុកភ្នំស្រុកក្នុងខេត្តបន្ទាយមានជ័យ មានការចិញ្ចឹមដង្កូវនាងតាមបែបផែនបច្ចេកទេសយ៉ាងសំខាន់ ពាក់កណ្ដាល

១-នៅសម័យនោះ ចាប់ពីអាយុ២០ឆ្នាំឡើងទៅ គេនិយមថាចាស់ហើយ ។ អ្នកនៅក្រមុំដែលមិនទាន់មានប្ដី គេហៅថាក្រមុំចាស់ឬក្រមុំសាវកែ (សាវកែពាក្យសៀមប្រែថាចាស់) ។



សម័យពាក់កណ្ដាលបុរាណ ។ គេជ្រលក់ពណ៌ដោយប្រើពណ៌ទិញពីបរទេស និងពណ៌ដែលផ្សំពីសំបករុក្ខជាតិ ក្រោមការឧបត្ថម្ភពីអង្គការអភិវឌ្ឍន៍ជនបទ ។

**រឿងព្រេងប្រវត្តិចិញ្ចឹមដង្កូវនាង** : ប្រជាជនចិនតំណាលតៗគ្នាថា កាលពីព្រេងនាយ មានកំលោះចិនម្នាក់មានរូបឆោមល្អពន់ពេក រកស៊ីដាំដំណាំ ។ ពួកស្រីៗចង់បានចៅនោះមកធ្វើជាប្ដី តែបុរសនោះមិនចង់បានប្រពន្ធសោះ ។ ដូច្នោះគេក៏គេចខ្លួនទៅនៅក្នុងព្រៃម្នាក់ឯង ដោយខំថែដើមឈើមួយដើម មានស្លឹកល្អគ្រប់ពណ៌ សំរាប់ទុកបេះផ្លែមកធ្វើជាអាហាររាល់ថ្ងៃ ។



រូបភាពស្ដីពីរឿងព្រេងប្រវត្តិចិញ្ចឹមដង្កូវនាង
(ដកស្រង់ចេញពីទស្សនាវដ្ដីតារ៉ាទី ខែ Se.p-Nov. 2006 ទំព័រ 95)

ថ្ងៃមួយមានមេអំបៅមួយចុះមកទុំលើរុក្ខជាតិនោះ ។ វេលាដែលឃើញមេអំបៅ បុរសនោះក៏ចាប់យកមកចិញ្ចឹមដាក់ក្នុងសំបុកស្លឹកឈើ បន្ទាប់មកមេអំបៅពង លុះយូរថ្ងៃបន្តិចក៏ញាស់ចេញជាដង្កូវបានចំនួន១២០ ។ មានស្រីក្រមុំពីរនាក់បានចូលទៅកន្លែងបុរសនោះ ហើយយកចិត្តទុកដាក់ថែទាំដង្កូវនោះ ។ ដល់ពេលធំឡើង ដង្កូវទាំង១២០ក៏វារទៅលើមែកឈើធ្វើសំបុកមានខ្សែៗពណ៌លឿងឆ្អៅ រួចក៏ស្លាប់អស់ទៅ ។ ប្រាំថ្ងៃកន្លងមក ស្ត្រីទាំងពីរនាក់នោះបានឃើញមេអំបៅបានហើរចេញពីសំបុកទាំង១២០ ដែលមានរាងនិងពណ៌ដូចជាមេអំបៅដែលពងកាលពីលើកមុន ។

រឿងនេះបានលេចឮដល់បណ្តានៃជនជាតិចិន ផ្អើលទៅមើលសំបុកមេអំបៅ ហើយមានចិត្តចង់បានសត្វនោះទៅចិញ្ចឹមនៅផ្ទះរៀងៗខ្លួន ។ តាំងពីថ្ងៃនោះមកប្រជាជនចិននាំគ្នានិយមចិញ្ចឹមដង្កូវនាងរហូតដល់បច្ចុប្បន្ននេះ។



# សំពត់ខ្មែរ

***ជំនាញ***តម្បាញ ពិសេសតម្បាញសំពត់សូត្រគឺជាប្រពៃណីរបស់ប្រជាជនខ្មែរ ដែលត្រូវបានគេថែរក្សាទុកបន្តគ្នាពីមួយជំនាន់ទៅមួយជំនាន់ ដូចជំនាញត្បាញកន្ទេលឬសិល្បៈដាប់ស្បែកធំ ស្បែកមធ្យម ស្បែកតូច ស្បែកពណ៌ ។ល។ វិធីបង្រៀននេះឆ្លងកាត់ការអនុវត្តន៍ជាក់ស្តែង គឺការបង្រៀនផ្ទាល់ក្នុងពេលធ្វើតែម្តង ។ ប៉ុន្តែក៏មានការវិវឌ្ឍន៍ពីមួយជំនាន់ទៅមួយជំនាន់ ទៅតាមការរកឃើញបន្តគ្នា ។ ជាក់ស្តែងក្នុងគ្រាឥឡូវនេះ យើងសង្កេតឃើញសំពត់ហូលមានការលើកគោមប្លែកៗលើសសម័យមុនៗ ។



*សំលៀកបំពាក់ និង ភួងសក់នារីខ្មែរសម័យអង្គរ*

*(ដកស្រង់ចេញពីទស្សនាវដ្តី វប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំទី៦លេខ៥ ខែធ្នូ ឆ្នាំ២០០០)*



*ការតុបតែងកាយសម័យលង្វែក*

*(ដកស្រង់ចេញពីទស្សនាវដ្ដី វប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំទី១លេខ៥ ខែធ្នូ ឆ្នាំ២០០០)*

ម៉្យាងទៀតពណ៌ ដែលពីដើមឡើយបានមកពីធម្មជាតិ ដោយយកឈើផ្សេងៗមកចាំងជាចំណាំងតូចៗ ស្ងោររំងាស់ឱ្យចេញពណ៌នោះ ឥឡូវនេះគេបានយកល័ខតីមីជំនួសវិញ ព្រោះងាយស្រួលរកហើយមិនសូវប្រឡាក់ជាប់ដៃយូរឡើយ ។ ប៉ុន្តែជាទូទៅ ល័ខដែលផលិតពីធម្មជាតិមានលក្ខណៈល្អជាង ។



សំពត់ខ្មែរ ជាស្នាដៃដ៏ល្អប្រណីត ដែលមានតម្លៃព្រមទាំងការនិយមស្លៀកប្រចាំជីវិតខ្មែរ ។ ស្ត្រីខ្មែរនិយមស្លៀកសំពត់សូត្រក្នុងពិធីមង្គល បុណ្យ



*ការតុបតែងកាយសម័យលង្វែក*

*(ដកស្រង់ចេញពីទស្សនាវដ្ដី វប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំទី១លេខ៥ ខែធ្នូ ឆ្នាំ២០០០)*

ទានផ្សេងៗ ពិសេសពិធីមង្គលការ ។ ឯបុរសនិយមស្លៀកសារុងសូត្រនៅផ្ទះ ។ ចំពោះអ្នកមានបណ្ដាស័ក្តិ តែងស្លៀកសំពត់សូត្រចងក្បិនក្នុងពេលមានពិធីបុណ្យជាតិធំៗ គ្រប់ពណ៌តាមថ្ងៃទាំងប្រាំពីរនៃសប្ដាហ៍ ។

សំពត់ខ្មែរមានច្រើនយ៉ាងដូចជា :

**សំពត់ផាមួង** : ជាកំណាត់សូត្រមាន លាត បន្តក់ មានជរជើង ឬ មានបន្តក់ហើយមានជរជើងទៀត ។ ស្ត្រីខ្មែរស្លៀកផាមួងនៅពេលថ្ងៃ តែ បើមានបន្តក់ហើយមានជរជើងភ្ជីផ្លេក បានសេចក្តីថាគេត្បាញពន្លេចពីសរសៃពណ៌មាសឬពណ៌ប្រាក់ គេសំរាប់ស្លៀកនៅពេលរាត្រី ។



*ការតុបតែងលំអកាយសម័យចតុមុខ សំលៀកបំពាក់ក្នុងពិធីបុណ្យតាមវត្តអារាម*
*(ដកស្រង់ចេញពីទស្សនាវដ្តី វប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំទី១លេខ៥ ខែធ្នូ ឆ្នាំ២០០០)*

**ហូល** : ជាប្រភេទសំពត់សូត្រ មានក្រឡាគោមច្រើនបែបឬជារូបភាពតាមធម្មជាតិផ្សេងៗ ។ ដូចជាផ្កាម្លូស ផ្កាម្ជិះ ផ្កាទទឹមឬសត្វពីងពាងអណ្តើក ហង្ស ដំរី ។ល។ សម័យបុរាណបុរសក៏ស្លៀកហូលដែរ តែគេ



រើសយកក្រឡាគោមធំៗ មានរូបរាជសីហ៍ ហង្ស នាគ ហើយត្បាញឱ្យមានជរជើង ។ ម៉្យាងទៀត ចំពោះអ្នកមានបណ្តាស័ក្តិពីថ្នាក់រដ្ឋមន្ត្រីទី១រហូតដល់ចៅហ្វាយស្រុកឬត្រកូលអភិជន បុរសៗនិយមស្លៀកហូលជាសំពត់សំឡុយឬចងក្បិន ពាក់អាវកត្រង់ឡេវមាសឬពាក់អាវសន្ទះបង់ក្រមា ក្នុងពេលបំពេញការងារ ។ គេតែងស្លៀកហូលនៅពេលថ្ងៃ ក្នុងពិធីបុណ្យសាសនាឬពិធីមង្គលផ្សេងៗ ។

**អន្លូញ** : ជាប្រភេទសំពត់សូត្រត្បាញឆ្នូតៗធំឬតូចឆ្មារ សម្រុងចម្រុះពីរឬបីពណ៌ គ្មានរចនាក្បាច់ទេ ។ តែមានសំពត់ខ្លះផ្នែកខាងក្រោម គេត្បាញជរជើង ។ គេស្លៀកអន្លូញចូលរួមក្នុងពិធីផ្សេងៗ ដែលមានលក្ខណៈសាមញ្ញសំរាប់ពេលថ្ងៃ ។

**សារុងស្បូត្រ** : ជាប្រភេទសំពត់ដែលគេជ្រលក់សូត្រច្រើនពណ៌ ហើយក៏មានទុកពណ៌សខ្លះដែរ ។ ពេលត្បាញគេឆ្លាស់ពណ៌ជាក្រឡាបួនជ្រុង ។ បុរសខ្មែរនិយមស្លៀកសារុងសូត្រនៅផ្ទះជាងស្ត្រី ។ សម័យដែលទើបតែកើតទម្រង់សិល្បៈអាយ៉ៃ សិល្បករច្រើនស្លៀកសារុងសូត្រច្រៀងអាយ៉ៃដោយសង្វើញទាញសារុងឱ្យខ្ចី ។ តែសិល្បការិនីច្រៀងជាដៃគូ គេមិនស្លៀកសារុងទេ គឺស្លៀកសំពត់ហូល ផាមួងជាដើម ។

**សារុងពុម្ព** : ជាប្រភេទសំពត់អំបោះដែលនាំចូលពីបរទេស មានប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី សៀម លាវជាដើម ។ ប៉ុន្តែនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ ក៏មានផលិតក្នុងស្រុកដែរ គឺមានផ្លាកសញ្ញាថា សារុងសេងថៃ ជាដើម។ បានជាគេហៅថាសារុងពុម្ព ព្រោះគេយកកំណាត់មួយផ្ទាំងៗ ប្រវែងសម្រុងប្រមាណ ១,១០ម៉ែត្រ និងទំហំប្រវែងប្រមាណ១,៧០ម៉ែត្រ មកបោះពុម្ពពីលើនូវរូបផ្សេងៗ ។ តែបច្ចុប្បន្ននេះគេមិនបានបោះពុម្ពទេ គឺ

ស្បាញជាកីៗហើយកាត់មួយបត់ បិទផ្លាកដាក់ថង់ផ្លាស្ទិកមួយសំពត់ៗ ។ សារុងពុម្ពភាគច្រើនស្ត្រីជាអ្នកស្លៀកនៅក្នុងផ្ទះ ។ ពីដើមអ្នកនៅទីក្រុងមិនអាចស្លៀកសារុងនេះចេញដើរក្រៅផ្ទះ ដូចសម័យឥឡូវនេះទេ ។ នេះគឺជាច្បាប់សុជីវធម៌ក្នុងសង្គមខ្មែរ ។ ប្រការនេះ កូនខ្មែរយើងយកមកអនុវត្តតាមលំអានដើម ព្រោះនោះគឺជាតម្លៃសម្រាប់ខ្លួនយើងផ្ទាល់និងសម្រាប់ប្រទេសជាតិដែរ ។ សូមបញ្ជាក់ថា : មិនចំពោះតែសារុងពុម្ពឬសារុងសូត្រទេ គឺរួមទាំងអាវប្លុំបស្លៀកពាក់ក្នុងផ្ទះឬសម្រាប់ពេលរាត្រី ទោះជាមានតម្លៃថ្លៃយ៉ាងណាក៏ដោយ ក៏យើងត្រូវតែកុំស្លៀកពាក់ចេញក្រៅផ្ទះឬទទួលភ្ញៀវនៅក្នុងផ្ទះទៀតផង ។

-**<u>សារបាប់</u>** : អ្នកខ្លះហៅចរបាប់ឬចារបាប់ឬជរបាប់ ។ ជាប្រភេទសំពត់សូត្រត្បាញរំលេចខ្សែទឹកមាសឬទឹកប្រាក់ ។ សម័យដើមប្រើជាសំលៀកបំពាក់សំរាប់ព្រះមហាក្សត្រក្នុងព្រះរាជពិធី ។ បច្ចុប្បន្នប្រើជាសំលៀកបំពាក់សំរាប់អ្នករបាំបុរាណនិងល្ខោនបាសាក់(សំរាប់តួអង្គធំៗ) ។ គេក៏មានប្រើសំរាប់កូនក្រមុំកូនកំលោះ ស្លៀកក្នុងពិធីមង្គលការដែរ ។

-**<u>ល្បើក</u>** : ជាប្រភេទសំពត់សូត្រឬអំបោះ ត្បាញលើកសាច់ពេញសុសដូចសារបាប់ដែរ តែរំលេចផ្កានិងជរដោយខ្សែអំបោះ ។ ក្បាច់នោះមានជារូបសត្វឬផ្កាផ្សេងៗលំអពាសពេញផ្ទៃ គេប្រើជាសំលៀកដូចសារបាប់ដែរ តែសំរាប់ពេលថ្ងៃ ។ គេក៏មានប្រើក្រាលលើតុ ជួនមានគ្របសពឬមឈូសផងដែរ ។ លោកស្រីព្រឹទ្ធសាស្ត្រាចារ្យរបាំបុរាណនៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ **រស់ គន់** ជាអតីតសិល្បការិនីនៅក្នុងរបាំព្រះរាជទ្រព្យ បានផ្តល់ពត៌មានថា សំពត់ល្បើកនេះគេក៏ស្លៀកជាសំពត់ចងក្បិន



ផងដែរ គឺលោកស្រីធ្លាប់ស្លៀកចងក្បិនទៅហាត់រៀនរបាំ តាំងពីក្មេងរហូតដល់ធំ ។

-**<u>ខៀន</u>** : ជាប្រភេទសំពត់ផាឱបឬទេសឯក ដែលមានសាច់រឹងហើយពោះពុម្ពរូបពណ៌ល្អិតៗ ។ សំពត់នេះនាំចូលពីក្រៅប្រទេស ។ ស្ត្រីចាស់ៗច្រើនស្លៀកចងក្បិនទៅចូលរួមក្នុងពិធីបុណ្យផ្សេងៗនៅឯវត្ត ។ យើងសង្កេតឃើញថាស្ត្រីចាស់ៗនៅខេត្តសៀមរាប បាត់ដំបង,... និយមស្លៀកខៀនចងក្បិនក្នុងជីវភាពធម្មតា ។

-**<u>ព្រៃលាត</u>** : ជាប្រភេទសំពត់សសុទ្ធឬមានផ្កា តែពណ៌សដដែល ។ គេយកព្រៃនោះមកបញ្ជាន់ល័ខពណ៌ខ្មៅ ជំនឹងញញួរឈើដោយកម្លាំងបុរស។ នៅពេលស្លៀកសាកពណ៌ គេយកសំពត់នោះទៅជ្រលក់ទឹកផ្លែមាក់ក្លឿសាចុះសាឡើងជាច្រើនដង ដោយហាលផ្ទាល់នឹងដី ពិសេសដីខ្សាច់ ។ វិធីធ្វើរបៀបនេះគេហៅថា «ផ្តែកមាក់ក្លឿ» ។ សំពត់នេះច្រើននាំចូលពីប្រទេសចិន ខ្មែរហៅថាសំពត់មុយអា ។ ពិសេសច្រើននាំចូលពីខេត្តសៀងហៃនៃប្រទេសចិន ដែលគេទទួលស្គាល់ថាល្អនោះ គេបានហៅបន្ថែមថា «មុយអាសៀងហៃ» ។ សំពត់នេះសំរាប់ស្លៀកក្នុងជីវភាពសាមញ្ញពិសេសក្នុងពេលហែសពឬការចូលរួមនៃការកាន់ទុក្ខជាមួយគ្រួសារអ្នកចែកឋាន ។

-**<u>សឹទ</u>** : ជាប្រភេទសំពត់អំបោះ មានក្បាច់នៅតាមជាយជារូបសត្វឬឆ្នូតៗទទឹង មានស្រឡាយមកពីសំពត់លាវ ។ តែសំពត់លាវច្រើនដេរជាបន្ទះបន្ថែមនៅតាមជាយជើងសំពត់ ។ សំពត់នេះគេច្រើនប្រើក្នុងជីវភាពរស់នៅជាធម្មតាឬប្រើក្នុងរបាំប្រពៃណី ដូចជារបាំត្រោកបៃលិន របាំគែន... ។ល។ គេឃើញមានត្បាញនៅព្រែកហ្លួង ។

ចំពោះសំពត់ស្បៀកចងក្បិន ដែលបានរៀបរាប់ខាងលើ ខ្មែរបុរាណនិយមបត់ជីបផ្នត់ៗស្បៀតទុក ។ នៅពេលលាស្បៀកមានភាពម៉ោងហើយមានភ្ជីល្អមើលទៀត ។

ម្យ៉ាងទៀត នៅសម័យមុនគឺមុនសម័យសាធារណរដ្ឋខ្មែរ ស្ត្រីខ្មែរដែលជាគ្រូបង្រៀនឬមន្ត្រីរាជការដែលធ្វើការនៅតាមស្ថាប័នធំៗ និយមស្លៀកសំពត់សូត្រទៅបំពេញការងារ សំពត់ទាំងនោះមាន : ហូល ផាមួង អន្លូញ ។ល។



# គុណគ្រូ

*ខ្មែរ*បុរាណតែងអប់រំណែនាំកុលបុត្រកុលធិតា ឱ្យទទួលស្គាល់និងគោរពប្រណិបត្តិចំពោះគ្រូ ដែលផ្តល់ចំណេះដឹងទូទៅឬផ្តល់ចំណេះបច្ចេកទេសផ្សេងៗជាប់ជាប្រចាំ ។ គ្រូដែលផ្តល់ចំណេះដំបូងផ្នែកខាងអក្សរសាស្ត្របានដិតជាប់លើអារម្មណ៍សិស្សខ្លាំងជាងគេ ។ គេតែងនិយមហៅថា គ្រូនមោព្រោះនៅសម័យដើម ការចាប់ផ្តើមរៀនដំបូងគេរៀនអក្ខរា ន-មោ ។

ដំណាក់កាលក្រោយមកទៀត គេចាប់ផ្តើមរៀនជាដំបូង ក-ខ គេក៏ប្រែមកហៅថាគ្រូ ក-ខ វិញ ។ អ្នកខ្លះនិយមហៅថា គ្រូចាប់ដៃ ព្រោះគ្រូបង្រៀនដំបូងនេះជាអ្នកបង្ហាប់ ហើយចាប់ដៃសិស្សឱ្យចេះកាន់ដីសឬខ្មៅដៃ ក្នុងការសរសេរជាដំបូងក្នុងជីវិតរបស់គេ ។

បន្ទាប់ពីធំពេញវ័យ ឆ្លងកាត់ការសិក្សាអក្សរលេខនព្វន្ត គេតែងបន្តការសិក្សានូវជំនាញបច្ចេកទេសផ្សេងៗ ដើម្បីទុកជាមុខរបរសំរាប់ចិញ្ចឹមជីវិតទៅអនាគត ។ គ្រូដែលផ្តល់នូវជំនាញឯកទេសនេះ គេទទួលស្គាល់ហើយឱ្យតំលៃជាទីបំផុត ព្រោះលោកគឺជាអ្នកដែលបានផ្តល់សមត្ថភាពឱ្យគេអាចគ្រប់គ្រងចិញ្ចឹមជីវិតរបស់ខ្លួនគេផ្ទាល់ មិនតែប៉ុណ្ណោះសោតរហូតដល់ក្រុមគ្រួសារទៀតផង ។ មិនត្រឹមតែចំពោះរូបគ្រូដែលជាអ្នកផ្តល់ចំណេះដឹងដោយផ្ទាល់នោះប៉ុណ្ណោះទេ គឺគ្រូផ្ទាល់នេះឯងតែងបានណែនាំឱ្យសិស្សរបស់ខ្លួនឱ្យគោរពដឹងគុណរហូតដល់គ្រូ ដែលបានផ្តល់ចំណេះដឹងដល់រូបលោកថែមទៀត ។

សម័យនោះ សិស្សម្នាក់ៗសុទ្ធតែបានយល់ច្បាស់ពីគុណដ៏ធំធេងរបស់គ្រូខ្លួន ហើយចាំយ៉ាងស្ទាត់ចំពោះកំណាព្យដែលបុព្វការីបានតាក់តែងមក ។

កំណាព្យនោះមានជាអាទិថា :

-គុណគ្រូមិនធូរមិនថយ នឹងគុណឪពុកម្តាយបង្កើតមុន
គុណគ្រូមិនស្រាលពេញជាធ្ងន់ ទុកដូចសំពៅវេចសំពាយ

ឬ

-វីគ្រូបាធ្យាយ ប្រដូចនូវម្តាយ ឪពុកយើងផង
ប្រិតប្រៀនប្រដៅ មិនឱ្យមានឆ្គង តាមដោយគន្លង
ព្រេងព្រឹទ្ធបូរាណ ។

ខ្មែរនៅមានការដឹងគុណដល់បុព្វបុរសជាគ្រូ ដែលគេមិនធ្លាប់ស្គាល់សោះ នូវចំណុចនេះ យើងអាចរាប់បញ្ចូលបានថាជាជំនឿអរូបីយ៍ ។ នោះគឺគ្រូតាមខ្សែជួរជំបួរ មានផ្នែកខាងឪពុក ផ្នែកខាងម្តាយ ព្រមទាំងគ្រូដើមម្នាក់ទៀត ។

គេមានជំនឿថា មនុស្សកើតមកតែងមានគ្រូមកតាមបង្រៀន ដូចជាពេលទារកនៅដេកម្នាក់ឯងហើយចេះសើច គេជឿថាមានអ្នកមកបង្រៀន ក្នុងន័យនេះអ្នកខ្លះហៅថា ម្តាយដើម ។ មានទារកខ្លះកើតមកមានពាក់ខ្សែធៀងម្ខាង មានគ្រូសង្ខារមកជួយឱ្យទារកនោះទៅអនាគតវៃឆ្លាត មានរិទ្ធិអំណាច មានយសស័ក្តិខ្ពង់ខ្ពស់ គេហៅគ្រូនោះថា គ្រូសង្ខារ... ។ ពេលខ្លះមានមនុស្សណាម្នាក់ឈឺ ហើយរកថ្នាំព្យាបាលចេះតែមិនប្រកបជាសះស្បើយ ។ ពេលនោះគេតែងរកហោរាគន់គូរមើល ហោរខ្លះទាយថាជម្ងឺនេះមើលមិនជា ព្រោះខុសគ្រូខាងឪពុក ឬខាងម្តាយ ឬគ្រូសង្ខារ... គេធ្វើឱ្យឈឺ ព្រោះខឹងអន់ចិត្តពីបញ្ហាអ្វីមួយឬអ្នកជម្ងឺនេះបានបោះបង់ចោលគេ



ភ្លេចគុណគេ មិននឹកនាដល់គេ....។ ពេលនោះគេត្រូវរៀបចំសែនព្រេនជាផ្លែឈើ នំនែក ហើយអុជទៀនធូបប្រកាសនិយាយបន់អង្វរសុំទោសចំពោះកំហុសឆ្គាំឆ្គង ដោយសូមកុំឱ្យប្រកាន់ខឹងនិងសូមឱ្យដកជម្ងឺចេញ ឱ្យបានជាសះស្បើយវិញកុំខាន ។ អ្នកមានជំនឿបែបខាងលើនេះ គេតែងរៀបរណ្តាប់ផ្សេងៗតាមជំនឿគៗគ្នាពីដូនតារៀងមក ហើយអុជធូបទៀនថ្វាយផ្លែឈើក្នុងមួយសប្តាហ៍ម្តង គឺរៀងរាល់ថ្ងៃសីល ។ ចំពោះអ្នកមានជំនាញបច្ចេកទេសផ្សេងៗ ពិសេសអ្នកឯកទេសរបាំបុរាណ យើងសង្កេតឃើញគេតែងគោរពដឹងគុណគ្រូមួយសប្តាហ៍ម្តងដែរ តែនៅរៀងរាល់ថ្ងៃព្រហស្បតិដែលគេហៅថាសំពះគ្រូ គឺសំពះរំលឹកទាំងគ្រូអរូបីយ៍ និងគ្រូដែលកំពុងបង្រៀនគេជារៀងរាល់ថ្ងៃ ។

សម័យដើម វត្តក៏ជាមជ្ឈដ្ឋានបណ្តុះបណ្តាលទាំងផ្នែកអក្សរសាស្ត្រក៏ដូចជាជំនាញផ្សេងៗដែរ ដូចជាជំនាញជាងឈើ ការសាងសង់ផ្ទះ ការព្យាបាលជម្ងឺតាមបែបបូរាណ ការតែងនិពន្ធ ករី....។ ចំពោះកូនស្រីពេលនៅជាកុមារី គេអាចទៅសិក្សានៅក្នុងវត្តបានដែរ តែនៅពេលពេញជំទង់ច្បាប់ប្រពៃណីខ្មែរមានការតឹងតែង នាងត្រូវបានទទួលការសិក្សាបន្តចំណេះពីម្តាយឬជីដូនវិញ មានជំនាញដេរប៉ាក់ ត្បាញកន្ទេល ត្បាញសំពត់សូត្រក្រមាឬឆ្នូបជាដើម ។ កុលបុត្រដែលត្រូវសិក្សាតែងស្នាក់នៅជិតស្និទ្ធជាប់លាប់ជាមួយគ្រូ ខ្លះនៅទីវត្តអារាមជាមួយគ្រូជាព្រះសង្ឃ ខ្លះនៅតាមគេហដ្ឋានគ្រូជាគ្រហស្ថ រួមទាំងការហូបចុកផង ។ សិស្សម្នាក់ៗតែងយកចិត្តទុកដាក់បំរើផ្គាប់ផ្គុនគ្រូ បំពេញចិត្តគ្រូឱ្យសប្បាយ ដែលអាចហុចផលទទួលបាននូវចំណេះវិជ្ជាប្លែកៗ ។ គេអនុវត្តគោលការណ៍នេះ គឺព្រោះគិតពីបញ្ហាអនាគត ថានឹងមានការប៉ិនប្រសប់លើមុខរបរ ដើម្បីឱ្យដំណើរជីវិត

របស់គេបានជួបប្រទះតែនឹងជោគជ័យ ។ ចំណែកឪពុកម្តាយដែលបាននាំកូនយកទៅប្រគេនព្រះសង្ឃឬលោកគ្រូនោះ ក៏តែងយកចិត្តទុកដាក់គោរពគ្រូណាស់ដែរ តែតែងរៀបរណ្តាប់ដែលមានលក្ខណៈជាទីសក្ការៈជូនគ្រូ គឺមានទៀន ធូប តែ ស្លា សំពត់ស ផ្លែឈើជាដើម ។ ឯកាយវិការនិងពាក្យសំដីក៏ប្រើក្នុងលក្ខណៈគោរព រួមទាំងពាក្យសន្យាថាខ្លួនមិនខឹងថ្នាំងថ្នាក់ទេ ប្រសិនបើគ្រូបានវាយវាត់ឬស្តីប្រដៅលើសលោះដល់កំរិតធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។ ពាក្យនេះបុរាណលោកតែងពោលថា «សូមលោកគ្រូកែច្នៃយ៉ាងណាក៏ធ្វើចុះ ឱ្យតែកូនខ្ញុំបានល្អ គឺពួកយើងខ្ញុំសុំតែស្បែក ឆ្អឹងនិងភ្នែកវិញទេ,...»។ បានសេចក្តីថា កូនធ្លាក់ខ្លួនស្លមអស់សាច់យ៉ាងណាក៏ដោយ ឱ្យតែបានជំរេះនិងប្រកបដោយគន្លងធម៌ ។ ក្នុងសម័យកាលដើមនោះ មិនត្រឹមតែកូនរាស្ត្រសាមញ្ញទេ សូម្បីតែកូនក្នុងត្រកូលអភិជនឬព្រះរាជវង្សានុវង្ស ក៏តែងគោរពដឹងគុណគ្រូណាស់ដែរ ។ ទោះជាមិនបានស្នាក់នៅហូបចុកដោយសារគ្រូ ហើយគ្រូបានទៅបង្រៀនដល់ព្រះដំណាក់ឬព្រះរាជវាំងក៏ដោយ ។

យោងលើឯកសាររបស់លោក **ឡុង សៀម** ក្នុងសិលាចារឹកដែលនិយាយពីពួកព្រាហ្មណ៍មាននាទីជាគរុសង្គមមនុស្សលោក ដែលខ្មែរបានទទួលឥទ្ធិពលពីឥណ្ឌា ព្រមទាំងរូបចំលាក់នៅប្រាសាទបាយ័ន ដែលបានឆ្លាក់រូបឥសីជាគ្រូបង្រៀនអង្គុយលើអាសនៈខ្ពស់ ឯសិស្សៗអង្គុយបត់ជើងនៅទីរាប ដៃកាន់សាស្ត្រាស្លឹករឹតអានអក្សរក្នុងលក្ខណៈគោរពលំទោន យកចិត្តទុកដាក់ស្តាប់គ្រូ បានបញ្ជាក់យ៉ាងច្បាស់ថា នៅសម័យអង្គរសិស្សគោរពគ្រូណាស់ ។ ម៉្យាងទៀតយោងលើរឿងព្រេងនិទានឬរឿងល្ខោនខ្មែរ ដែលសំដែងតាមទំរង់បុរាណផ្សេងៗ តែងបានសំដែងក្នុងពេលបច្ចុប្បន្ននេះ ក៏



បានធ្វើឱ្យយើងចាប់អារម្មណ៍យល់ពីការសិក្សា និងការគោរពដឹងគុណគ្រូនៅសម័យព្រេងនាយបានដែរ ។

<u>ឧទាហរណ៍</u> :

- <u>**ការបំរើគ្រូ**</u> : មានការគក់ប្រចាំ ដាំស្ល ដាំទឹកតែជាដើម ។ ដែលក្នុងនោះមានសិស្សខ្លះខ្ជិលរៀន បានត្រឹមតែចេះដាំទឹកតែជូនគ្រូ ។ តួសិស្សកំជិលនេះច្រើនជាតួត្លុក ហើយគេដាក់ឈ្មោះថាអាតាំង ។ អាតាំងនេះឥតបានទៅជាស្អីនឹងគេទេ· បានត្រឹមតែនៅដាំតែជូនគ្រូ តែក៏គេចិតនៅក្នុងចំណោមសិស្សដែលមានសីលធម៌ល្អ ក្នុងការគោរពដឹងគុណគ្រូដែរ ។
- <u>**ការគោរពដឹងគុណគ្រូ**</u> : តួឯកដែលរៀនពូកែ បានរៀនចេះចប់គ្រប់វិជ្ជាពីគ្រូ ភាគច្រើនសុទ្ធតែជាអ្នកមិនរមិលគុណគ្រូ ។ គេនោះជាពូជមនុស្ស បានសេចក្តីថា ជាពូជដ៏ល្អត្រឹមត្រូវគឺតំណាងឱ្យពូជខ្មែរ ។ មុននឹងបញ្ចេញស្នាដៃអ្វីមួយ សុទ្ធតែពោលពាក្យទឹកដល់គុណគ្រូដែលបានបណ្តុះបណ្តាលខ្លួនជាមុនសិន ទើបចាប់ដំណើរការឬប្រើការវិជ្ជារបស់គ្រូ ។ ក្នុងការបណ្តុះបណ្តាលរួមគ្នានោះ ក៏មានសិស្សអាក្រក់រមិលគុណគ្រូដែរ តែពួកនោះសុទ្ធជាពូជពួកយក្សា ជាពូជមិនល្អ គឺតំណាងឱ្យពូជដទៃទៀតផ្សេងពីខ្មែរ ។

ប្រសិនបើចង់និយាយពីសម័យមុនអង្គរ ឬរហូតដល់សម័យបុរេប្រវត្តិវិញ ខ្មែរក៏មានសីលគោរពដឹងគុណគ្រូដែរ ។ តាមកំណាយដែលគេបានរកឃើញវត្ថុនានា បានធ្វើឱ្យអ្នកបុរាណវិទ្យាសន្និដ្ឋានថាខ្មែរគោរពបុព្វបុរសខ្លួនណាស់ ។ គេតែងដាក់ក្នុងផ្នូរជាមួយសពនូវវត្ថុប្រើប្រាស់ឬជាទីសក្ការៈជូនអ្នកដែលបានចែកឋានទៅ ។ ម៉្យាងទៀតដូចន័យដែលបានរៀបរាប់មកថា ខ្មែរមានជំនឿអរូបីយ៍នោះ ខ្មែរមានវង់ភ្លេងមួយដែលមានជីវិតរាប់ពាន់

ឆ្នាំ បានចិតថេរដល់បច្ចុប្បន្នសំរាប់លេងជូនវត្ថុសក្តិសិទ្ធិ ។ គេមានតែង បទសំរាប់លេងជាច្រើន ដែលក្នុងនោះមានបទសំរាប់លេងថ្វាយគ្រូ ដូចជា បទអញ្ជើញគ្រូឬនិមន្តគ្រូ ។ បានសេចក្តីថាគេអញ្ជើញគ្រប់គ្រូទាំងអស់មក សោយក្រយានិងស្តាប់ភ្លេងកំសាន្ត ។ ក្នុងនោះមានអញ្ជើញទាំងគ្រូតូច មានទាំងគ្រូធំ មានទាំងគ្រូនៅលើកំពូលភ្នំ គ្រូនៅក្នុងព្រៃ....។ ទន្ទឹមនោះ ក៏មានបទហៅឈ្មោះតួអង្គចំៗតែម្តងដែរ ដែលក្នុងនោះក៏មានបទសំរាប់ ថ្វាយគ្រូធំឬសម្តេចព្រះគ្រូជាដើម ។...

មកដល់ពាក់កណ្តាលសតវត្សទី២០នៃគ្រឹស្តសករាជ គឺក្រោយសម័យ អាណានិគមនិយមបារាំងផុតរលត់ទៅ ។ ពោលគឺខ្មែរបានឯករាជ្យក្នុងឆ្នាំ ១៩៥៣ រាជរដ្ឋាភិបាលបានរៀបចំកសាងសាលារៀនជាបណ្តើរៗជាច្រើន ពាសពេញប្រទេស ។ ពេលនោះប្រជារាស្ត្រខ្មែរបានងាកបែរមកឱ្យកូនចូល រៀនតាមសាលានានាវិញ ដែលអាចឱ្យគេស្នាក់នៅតាមគេហដ្ឋានរៀងៗខ្លួន ពេលនោះការដឹងគុណគ្រូបានឃ្លាតរវាតថយចុះខ្លះ ព្រោះគ្រូលែងទទួលបន្ទុក គ្រប់គ្រងនិងផ្តល់ជំរកឬការហូបចុកទៀតហើយ ។ ពេលនោះគេសង្កេត ឃើញថា សិស្សមិនសូវទិញសំភារៈឬនំចំណីជូនគ្រូក្នុងលក្ខណៈជាការដឹង គុណច្រើនទេ ។ ប៉ុន្តែសីលធម៌នៃការគោរពគ្រូនៅតែមាន ព្រោះមាតាបិតា មិនបានភ្លេចពីភារកិច្ចក្នុងការអប់រំបុត្រធិតាឡើយ ។ លោកទាំងនោះ ស្រឡាញ់កិត្តិយស កេរ្តិ៍ឈ្មោះណាស់ លោកតែងចង់ឃើញឬតាមដានឱ្យ កូនប្រព្រឹត្តតែអំពើល្អ ។ លោកចង់ឮសំដីសរសើរពីគ្រូឬអ្នកដទៃ ចំពោះ កូនដែលជាតំណាងឱ្យវង្សត្រកូលមានឈ្មោះក្រអូបសុះសាយច្រាស់ខ្យល់ ។ ឯសិស្សវិញ ម្នាក់ៗសុទ្ធតែស្តាប់បង្គាប់និងគោរពគ្រូ មិនហ៊ានដើរកាត់មុខគ្រូ ឬដើរមុនគ្រូឡើយ ។ ប្រសិនបើជាការចាំបាច់ខានមិនបាន តែងប្រើកិរិយា



បថអោនលំទោនដែលតំណាងឱ្យន័យសុំទោសឬសុំអធ្យាស្រ័យអនុគ្រោះ។..

ចូលមកដល់សម័យសាធារណរដ្ឋខ្មែរលោកលន់នល់(១៩៧០-៧៥) ជីវ ភាពប្រជារាស្ត្រខ្មែរបានធ្លាក់ចុះ ព្រោះដោយសារនយោបាយឬសង្គ្រាម ។ ពិសេសជីវភាពរបស់គ្រូ បើប្រៀបធៀបប្រាក់បៀវត្សរបស់គ្រូនៅសម័យមុន (រួមទាំងប្រាក់គរុកោសល្យនិងប្រាក់បំណាច់ផ្សេងៗទៀត) ឃើញថាមាន កំរិតខ្ពស់ជាងមន្ត្រីរាជការទាំងឡាយពីរឬបីដង បានផ្តល់ឱ្យជីវភាពរបស់គ្រូ ចិតក្នុងកំរិតមួយខ្ពង់ខ្ពស់និងថ្លៃថ្នូរ ។ ពីមួយថ្ងៃទៅមួយថ្ងៃ កំរិតជីវភាព របស់ប្រជារាស្ត្របានដាំក្បាលធ្លាក់ចុះដូចព្រួញ ។ អំពើពុករលួយកើតមាន ពាសពេញប្រទេស ពិសេសលើជួរអ្នកដឹកនាំជាន់ខ្ពស់ផ្នែកក្រសួងការពារ ជាតិ ។ ឯគ្រូខ្លះក៏កើតគំនិតនិងធ្វើសកម្មភាពស៊ីសំណូកសូកប៉ាន់ពីសិស្សដែរ តំលៃគ្រូទាំងអស់បានធ្លាក់ចុះ ព្រោះគេបានវាយតំលៃសរុប ។ ម៉្យាងទៀត គ្រូដែលស្អាតស្អំ ច្រើនមានជីវភាពទន់ទាប គ្មានសំភារៈទំនើបៗអន់ថយ ជាងសិស្សនោះ សិស្សខ្លះកើតចិត្តប្រមាថមើលងាយគ្រូ ។...

សម័យកម្ពុជាប្រជាធិបតេយ្យឬសម័យប៉ុលពត(១៩៧៥-៧៨)ជាសម័យ ខ្មៅងងឹត គ្រូជាសត្រូវនឹងរបបនេះណាស់ ព្រោះគេយល់ថាគ្រូជាអ្នកចេះ ដឹង ជិះជាន់លើពួកកសិករឬអ្នកក្រីក្រ..... ពិសេសមិនបានបញ្ចេញកម្លាំង កាយ រស់នៅដោយស្រណុក មិនចេះធ្វើស្រែចំការ ចាំតែហូប... ។ ហេតុ ដូច្នេះហើយបានជាគ្រូនៅរស់រានមានជីវិតតិចតួចណាស់ ។ អ្នកដែលបាន នៅរស់គឺដោយសារលាក់ប្រវត្តិរូបឬមិនទាន់ដល់ពេលយកទៅសំលាប់ ។...

ចូលដល់សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា គ្រូដែលនៅសេស សល់ ខ្លះបានចូលមកបំរើការតាមជំនាញ ។ ខ្លះទៀតក៏ងាកបែកទៅបំរើ ការងារផ្សេងៗវិញ ដែលច្រើនមានតួនាទីខ្ពស់គួរសម មានខ្លះទៀតឡើង

ឋានៈខ្ពង់ខ្ពស់ទៀតផង ។ ហេតុនេះហើយបានជាធ្វើឱ្យការខ្វះគ្រូបង្រៀនកាន់តែមានកំរិតខ្ពស់ ។ ភាពកង្វះគ្រូដ៏ច្រើនដូច្នេះហើយ បានជាជំរុញស្ថានការណ៍ជ្រើសរើសគ្រូឱ្យមកទទួលការបណ្តុះបណ្តាលជំនាញគ្រូ ក្នុងរយៈពេលខ្លីៗ ។ សីលធម៌និងការយល់ពីតំលៃនៃតួនាទីឬជំនាញគ្រូមានកំរិតទាប ។ ម៉្យាងទៀតជីវភាពនៃប្រជារាស្ត្រខ្មែរ ក៏ដូចជាមុខរបរគ្រូដែរ មានសភាពដុនដាបយ៉ាងខ្លាំងរួមទាំងសីលធម៌ក្នុងសង្គមផង ។ ក្នុងកាលៈទេសៈនេះបានធ្វើឱ្យគ្រូគ្មានតំលៃឬគ្មានន័យសោះក្នុងដួងចិត្តសិស្ស ។ ភាគច្រើនគេច្រើននាំគ្នាបន្ទោសថា សីលធម៌សង្គមដាបចុះខ្លាំង គឺមកពីការទទួលឥទ្ធិពលក្នុងសម័យប៉ុលពតបន្សល់ទុកឱ្យ ។ បញ្ហានេះជាកត្តាសមរម្យណាស់ តែនៅក្រោយសម័យប៉ុលពត អ្នកដឹកនាំក៏បានបណ្តែតបណ្តោយតាមសាច់រឿង គឺមិនបានខិតខំប្រឹងប្រែងរកវិធានការណ៍កាច់ជាបណ្តើរៗ មករកផ្លូវត្រូវវិញដែរ ។ ប្រាក់ចំណាយទៅលើការការពារជាតិ គេគិតជាអទិភាពទី១ ដែលមានកំរិតខ្ពស់ខុសឆ្ងាយពីបញ្ហាអប់រំ ដែលជាបញ្ហាសំខាន់និងចំបងដែរ ឬមិនបានចុចឱ្យឈានដល់កំរិតមួយ អាចធ្វើឱ្យទទួលផលគួរជាទីសង្ឃឹមឡើយ ម៉្យាងទៀតថ្នាក់ដឹកនាំជាន់ខ្ពស់ភាគច្រើន ដែលជាគំរូឬជាអ្នកមានឥទ្ធិពលលើសង្គម មិនបានអប់រំកូនចៅសាច់ញាតិខ្លួនឯងទេ ថែមទាំងកាន់ជើងឬបណ្តែតបណ្តោយឱ្យសាបព្រួសអំពើអសីលធម៌ពាសពេញប្រទេស ឬពាសពេញសាលារៀន ។ សិស្សនោះមិនបានគោរពគ្រូ ហើយថែមទាំងចំអកឬដាក់ងារថ្មីឱ្យគ្រូ ដើម្បីជាការសើចលេងសប្បាយឬប្រមាថគំរាមកំហែងគ្រូជាពាក្យសំដី មានខ្លះរហូតដល់កំហែងប្រើអាវុធទៀតផង ។ គេកាន់អាវុធបញ្ជាឱ្យគ្រូសំពះគេ វារ លូន ដើរ ក្រាប...។

បញ្ហាមួយទៀត គេច្រើននាំគ្នានិយាយថាគឺមកពីកត្តាសេដ្ឋកិច្ច ។ នៅ



ស្រុកខ្មែរបច្ចុប្បន្ន ក្នុងគ្រួសារថ្នាក់មធ្យមចុះក្រោម ម្តាយឪពុកមានការមមាញឹកខ្វល់ខ្វាយតែពីការរកស៊ី ដើម្បីផ្គត់ផ្គង់គ្រួសារ គឺធ្វើយ៉ាងណាឱ្យតែបានហូបចុកសិន ដោយបានបោះបង់ចោលការអប់រំអស់រលីង ។ ចុះបច្ចុប្បន្ននេះដែរ នៅប្រទេសជឿនលឿន ដែលមិនបានចោទលើបញ្ហាសេដ្ឋកិច្ចគ្រួសារប៉ុន្មានដែរ ក៏កើតមានកូនសិស្សសាហាវអសីលធម៌ដែរ ?។ បញ្ហានេះអាចមកពីឪពុកម្តាយមមាញឹកក្នុងការងារ និងគ្មានពេលទៅជិតស្និទ្ធស្នាលអប់រំមើលការខុសត្រូវ ។ ម៉្យាងទៀតសង្គមគេបើកដៃឱ្យកូនមានសិទ្ធិសេរីភាព ។ គេមានពេលឱ្យសង្គមបរិយាកាសអប់រំ ដែលយើងច្រើននិយាយថាការសេពគប់ឬការអូសទាញពីវប្បធម៌សិល្បៈពាលាអាវាសែ ឬមិត្តភ័ក្តិខិលខូច... ។ ខ្លះទៀតគេចោទថាមកពីប្រទេសខ្មែរមានសង្គ្រាម ! ។ ចុះបុរាណណាចារ្យក្រោយសម័យអង្គរ តែងរត់ចុះឡើងគេចពីសង្គ្រាមរាប់សតវត្សមកហើយ ម៉េចក៏លោកនៅតែមានសីលធម៌គោរពដឹងគុណគ្រូ ? ។

យើងខ្ញុំយល់ថា បញ្ហាក្រីក្របានធ្វើឱ្យសីលធម៌ចុះខ្សោយមែនពិត តែការអប់រំក៏មិនបានទាមទារចំណាយប្រាក់កាសសុទ្ធសាធដែរ ។ ដូចជាសម័យប៉ុលពត របបនេះបានអប់រំកុមារឱ្យដើរតាមគន្លងអង្គការរបស់គេ ដោយក្តីគោរពតាមបញ្ជាបំផុតបាន ដោយគ្មានការចាយវាយប្រាក់កាសទេ ។ បញ្ហានេះអាចឈរលើសមត្ថភាពក្នុងការយល់ដឹងច្បាប់ឬវិន័យ ឬសិល្បវិធីរបស់អ្នកគ្រប់គ្រង ពិសេសត្រូវសំដែងឱ្យគេមានជំនឿ មើលឃើញនិងយល់ច្បាស់ពីបំណងរបស់យើង ដែលអាចឱ្យគេកើតក្តីសង្ឃឹមពីអនាគតរបស់គេថា ច្បាស់ជាទទួលបាននូវភាពភ្លឺស្វាងឬខ្ពង់ខ្ពស់ ។ យើងសង្កេតឃើញថា នៅពេលវិលត្រឡប់ពីរបបប៉ុលពតវិញ មនុស្សម្នាក់ៗចិតក្នុងសភាពធ្ងឹងនិងខ្ទាប អាចថាឈរជាកណ្តាលឬជាក្រដាសសទទេក៏បានដែរ ។ ពេលនោះ

គេថ្មៃទៅណាបានតាមចិត្តប្រាថ្នា ។ បើបើកដៃឱ្យទៅរកផ្លូវអាក្រក់ងាយស្រួលបំផុត គឺមិនខុសពីស្មៅឬរុក្ខជាតិដែលដុះក្នុងគំនាបដុំថ្មឬដុំឈើទេ នៅពេលដកចេញ វាដុះក្រវិក្រវក់តាមអំពើចិត្តប្រសិនបើយើងមិនតំរែតំរង់។

ស្ថិតក្នុងស្ថានភាពបច្ចុប្បន្ន ដែលសិស្សភាគច្រើនមិនគោរពឬដឹងគុណគ្រូនេះ យើងខ្ញុំបានសង្កេតឃើញថា នៅមានសិស្សល្អតិចតួចដែលនៅដើរតាមលំអានពីបុរាណខ្លះដែរ ។ ភាគច្រើននៃសិស្សល្អនោះ គឺច្រើនចិកនៅក្នុងត្រកូលដែលមានសារជាតិយល់ច្បាស់ពីតំលៃនៃអំពើអាក្រក់និងអំពើល្អ។ ពូជនេះក្នុងរបបប៉ុលពត នៅសល់តិចតួចបំផុត ។ ម៉្យាងទៀតនៅមានសិស្សភាគច្រើនមួយពួកទៀត ដែលបានសិក្សាឯកទេសរបាំបុរាណ គេនៅស្តាប់បង្គាប់ គោរពកោតខ្លាចនិងដឹងគុណគ្រូណាស់ ។ គេប្រឹងប្រែងយកចិត្តគ្រូព្រោះគេចង់បានចំណេះ ជាតំរេះដែលអាចក្លាយទៅជាអ្នករបាំដ៏មានសមត្ថភាពខ្ពស់,,,,។ តែការណ៍នេះក៏អាចកើតចេញពីប្រពៃណី ដែលជាទម្លាប់បន្តពីគ្រូក្មេងៗ គោរពគ្រូចាស់ៗ ដែលជាគំរូដ៏ល្អឬជាច្បាប់សីលធម៌នៃឯកទេសរបាំបុរាណដែរ ។ រៀងរាល់ថ្ងៃព្រហស្បតិ៍ បើគេមិនបានធ្វើពិធីសំពះគ្រូជាធំដុំទេនោះ ក៏សិស្សទាំងអស់តែងយកទៀន ធូប ផ្កាទៅក្រាបសំពះគ្រូដែរ ។ រាល់ពេលរដូវបុណ្យទាន ពិសេសបុណ្យចូលឆ្នាំថ្មីនិងបុណ្យភ្ជុំបិណ្ឌ សិស្សទាំងនោះតែងទិញសំភារៈឬនំចំណី ផ្លែឈើ ក្រណាត់.. យកទៅជូនគ្រូជាចាំបាច់ដោយមិនខានឡើយ ទោះតិចឬច្រើន យោលទៅតាមលទ្ធភាពនៃគ្រួសាររបស់សិស្សម្នាក់ៗ ។

# សម្លរចំណូលចិត្តខ្មែរ

***តាម***ការសង្កេតនិងការសាកសួរពត៌មានពីប្រជារាស្ត្រខ្មែរសុទ្ធ ពិសេសអ្នករស់នៅជនបទ ក្នុងមួយខែសាមសិបថ្ងៃ គេបរិភោគសំឡម្ជូរម្ដៃថ្ងៃយ៉ាងតិច ។ ចំនួននេះមិនបានរាប់បញ្ចូលនឹងម្ហូបដែលមានរសជូរផ្សេងៗទៀតទេ។ ដើម្បីរក្សាចំងាញ់ឱ្យពេញមាត់ គឺមិនឱ្យធុំនឹងភាពច្រំដែល គេតែងផ្លាស់ប្ដូរបន្លែឬផ្លែឈើជារៀងរាល់ថ្ងៃ សំរាប់ស្ងសំឡម្ជូរនោះ ។ បន្លែឬផ្លែឈើដ៏ច្រើនដុះពាសពេញផ្ទៃប្រទេសខ្មែរ ភាគច្រើនសុទ្ធតែអាចឱ្យគេយកមកស្ងម្ជូរបាន ។ បន្លែដុះក្នុងទឹកមានជាអាទិដូចជាត្រកួន កញ្ឆែត ត្រកៀត កំពឹងពួយ ក្តាត ព្រលឹត រំចង់ ក្រអៅឈូក ។ល។ ឯបន្លែដែលដុះលើដីមានត្រួយល្ពៅ ស្លឹកថ្នឹង ស្លឹកសណ្តាន់ ស្លឹកម្កាក់ ត្រួយអំពិល ។ល។ ចំពោះផ្លែឈើវិញមាន គ្រប់ ចេកខ្ចីឬត្រយូងចេក ល្ពៅ ត្រឡាច ឃ្លោក ប៉េងប៉ោះ ម្នាស់ ល្ហុងខ្ចី ។ល។ នៅពេលស្ងឆ្អិនហើយ គេតែងភ្លក្សផ្ទៀងផ្ទាត់ថាតើសំឡនេះគ្រប់គ្រាន់គ្រឿងគ្រៅហើយឬនៅ ? ប្រសិនបើគ្រប់ពេញចិត្តហើយ គេតែងពោលថា «ឆ្ងាញ់ណាស់ ! ជូរជ្រះ !..» តែបើជូរជ្រុលគេថា «អូយ ! ជូរហិញ !..» ។ បើសិនមិនសូវជូរគេថា «ស្មើរម្ជូរបន្តិច !» នោះគេនឹងដាក់ម្ជូរបន្ថែម ដើម្បីឱ្យបានរសជូរជ្រះ ។ អ្នកដែលទើបងើបបានស្រាកស្រាន្តពីជំងឺ ពិសេសជម្ងឺគ្រុនក្តៅឬសាយ គេតែងស្ងសំឡម្ជូរឱ្យហូប ដោយគេនិយាយលួងថា «ប្រឹងងើបឡើង ហូបសំឡម្ជូរនេះបន្តិចមើល ឆ្ងាញ់ណាស់ ជូរជ្រះមាត់...!» ។ ភាគច្រើននៃអ្នកជម្ងឺ



នេះច្រើនសាបឬល្វីងមាត់ នៅពេលហូបសំឡម្ជូរហើយ គេតែងស្រឡះខ្លួនមាត់បាត់រសសាបឬល្វីង ហើយហាក់ដូចជាមានកម្លាំងកំហែងបានស្រាកពីរោគា ។



*ផ្លែអំពិលជូរ*

ក្រៅពីការស្ងសំឡម្ជូរ ខ្មែរបានប្រើរសជូរនេះដោយការ :

-**ស្ងោរជ្រក់** : ជ្រក់ត្រី ជ្រក់សាច់គោ ជ្រក់ក្រៅឆ្នាំង... ដែលភាគច្រើនគេប្រើផ្លែក្រូចឆ្មារឬផ្លែអំពិលទុំ ។

-**ញាំ** : ញាំផ្លែក្រូចថ្លុង ផ្លែម្កាក់ ផ្លែស្វាយខ្ចី ផ្លែប៉េងប៉ោះ ស្ពៃក្តោបស្ពៅ.... ។

-**ជ្រក់** : យកបន្លែឬផ្លែឈើមកត្រាំ មានត្រសក់ ល្ហុង ស្វាយខ្ចី មមៀញ ម្ទេសប្លោកឬសត្វអង្រ្កង....។

-**ផ្លារ** : យកសាច់ត្រីឬសាច់គោមកច្របាច់ជាមួយទឹកខ្មេះឬក្រូចឆ្មារឱ្យឆ្អិន ហើយដាក់រួមផ្សំជាមួយបន្លែផ្សេងៗ ។

-**បុក** : បុកត្រីងៀតឬត្រីអាំង ត្រីឆ្អើរ កំពិស.... ជាមួយផ្លែអំពិលខ្ចីស្វាយខ្ចី ផ្លែល្ហុងខ្ចីដោយច្របាច់ម្ជូរក្រូចឆ្មារឬអំពិល....។

-**ជ្រលក់** : ធ្វើទឹកម្ជូរសំរាប់ជ្រលក់សាច់ផ្សេងៗ ដោយផ្ទាល់ឬផ្ទាប់ជាមួយបន្លែគ្រប់មុខ.... ។ ឬជ្រលក់ត្រីអាំង ត្រីឆ្អើរជាមួយទឹកត្រីដាក់ម្ជូរមានស្វាយខ្ចី អំពិល ម្កាក់ជាដើម ។

-**ទឹកគ្រឿងឬទឹកគាពិ** : សុទ្ធតែត្រូវប្រើគ្រឿងម្ជូរ ។

-**ផ្អកឬម្ទាំ** : ធ្វើទុកផ្អាប់ឱ្យជូរ ហើយប្រើម្ជូរបន្ថែម ។

-**ប្រហុក** : ចំហុយឬកប់ឬចិញ្ច្រាំប្រហុកឆៅដាក់គ្រឿងឬអាំង ក៏តែងប្រើម្ជូរដើម្បីលើករសចំងាញ់..... ។

ចំពោះការប្រើពាក្យទឹកត្រីផ្អែម ដើម្បីជ្រលក់ជាមួយស្ពៃ បន្លែឬសាច់ផ្សេងៗទៀតនោះ គេមិនដែលប្រើតែរសផ្អែមដោយគ្មានប្រើរសជូរទេ គឺគេត្រូវប្រើម្ជូរច្រើនដែរ គ្រាន់តែឱ្យរសផ្អែមលោតខ្លាំងបន្តិច ។

នៅពេលរសៀល ពិសេសក្មេងស្រីៗតែងនិយមជួបជុំគ្នាហូបម្ជូរលេងដើម្បីជជែកកំសាន្តឬសំរន់ភាពចង់ម្ជូរ ព្រោះគេតែងជួបប្រទះផ្លែឈើជូរៗនៅក្នុងបរិយាកាសជុំវិញនៃជីវិតរបស់គេ ។ ក្មេងស្រីៗទាំងនោះភាគច្រើនគេតែងសាបមាត់ ចង់ម្ជូរនៅពេលជិតមានរដូវ ។ បើម្នាក់ជិតមាន ក៏តែងអូសទាញអ្នកផ្សេងឱ្យចូលរួមដែរ ព្រោះរសជូរនេះមានឥទ្ធិពលអាចទាក់ទាញចិត្តគេបាន ។ ការទទួលទានម្ជូរនេះគេមិនសូវប្រកាន់ទេ ពេលឃើញគ្នីគ្នាគេតែងហៅគ្នាភ្លាមៗឱ្យចូលរួម ឬបើអ្នកកំពុងទទួលទានរវល់តែសើចគួរសមភ្លេចអញ្ជើញ អ្នកនោះអាចដើរមកចូលរួមហូបដោយឥតខ្មាស់បាន គេមិនអាចចោទថាជាមនុស្សឥតរបបទេ ។ ការចង់រសម្ជូរនេះក៏ច្រើនកើតមានចំពោះស្ត្រីមានផ្ទៃពោះក្នុងរវាង១ខែឬ២ខែដែរ ។ អ្នកនោះច្រើនសាបមាត់ចង់ក្អួតចង្អោរ ហើយចង់ហូបម្ជូរយ៉ាងខ្លាំងស្ទើរគ្រប់ពេល រហូតដល់ពេលទទួលទានដំណេក ។ ចំពោះការហូបម្ជូរនៅពេលរសៀលវិញនោះ គេច្រើន



ហូបម្ជូរលាយជាមួយនឹងម្ទេស បានសេចក្ដីថាដើម្បីកុំឱ្យជូរខ្លាំងពេកនិងដើម្បីកុំឱ្យឈឺពោះផង គេតែងប្រើផ្លែម្ជូរតាមការដែលមាន ហើយបានដើររកផ្លែឈើណាដែលមានរសជាតិចត់ ដូចជាចេកខ្ចី សេដាខ្ចី ល្ហុងខ្ចីជាដើមមកផ្ទាប់លាយជ្រលក់ជាមួយអំបិលឬទឹកត្រី ទឹកប្រហុកឬប្រហុកចិញ្ច្រាំ....។

នៅពេលកំពុងបុកអំបិលលាយជាមួយម្ទេស ឬចិញ្ច្រាំប្រហុកឬលាយទឹកត្រីជាមួយស្ករ ដែលបានប្រើពេលឱ្យគេរង់ចាំនោះ ទាំងអ្នកបុកឬលាយទាំងអ្នកអង្គុយមើល តែងអន្ទះសារស្រក់ទឹកមាត់ឬលេបទឹកមាត់ក្លឹកៗគួរឱ្យអស់សំណើច ។ ហេតុការណ៍នេះជាចំណងរិតសាមគ្គីភាព ដែលអាចទុកជាអនុស្សាវរីយ៍ពីកុមារភាពរហូតដល់ចាស់រៀងៗខ្លួន ។ រឿងហេតុនេះច្រើនកើតមានផងដែរចំពោះកុមារាកុមារីគង្វាលគោក្របី គឺមុនពេលចេញដំណើរ គេតែងវេចជាយក្រមានូវអំបិលឬខ្ទប់ប្រហុក ដើម្បីយកទៅជ្រលក់ម្ជូរផ្សេងៗដែលដុះនៅតាមគុម្ពោតព្រៃ ក្នុងពេលគេត្រូវបំពេញការងារបណ្ដើរហើយប្រមូលគ្នាជុំៗដើម្បីហូបម្ជូរកំសាន្តសប្បាយ ។

សភាពការណ៍នេះកើតមានឡើងបាន ក៏ព្រោះយោលតាមភូមិសាស្ត្រទឹកដីដែលបានផ្ដល់កំណើតឱ្យគេ ។ ទឹកដីនេះបានអំណោយផលអាចដុះបាននូវរុក្ខជាតិដ៏សំបូរបែប ដែលក្នុងនោះយើងបានឃើញរុក្ខជាតិដែលចេញជាស្លឹក ផ្កាផ្លែមានរសជូរដ៏ច្រើន ។ នៅរាល់ខែ គឺចាប់ពីខែមួយចូលទៅខែមួយ ធម្មជាតិបានបញ្ចេញផលម្ជូរជាបន្តបន្ទាប់រដឹក ដើម្បីផ្គត់ផ្គង់បំពេញចិត្តខ្មែរ ។

តាមការសង្កេតនៅគ្រប់ទីផ្សារ ចំពោះម្ជូរដែលអ្នកដឹកជញ្ជូនបានយកមកលក់នៅទីផ្សារជារៀងរាល់ថ្ងៃខែនោះ មានជាអាទិដូចតទៅ :

- **អំពិលជូរ**មាន : ផ្កា ត្រួយស្ងួក ផ្លែក្តឹប ផ្លែទុំនោះ បានផ្តល់ឱ្យរហូតជាបន្តបន្ទាប់ ចាប់ពីដើមឆ្នាំរហូតដល់ចុងឆ្នាំ ព្រោះពេលវាទុំគេឆ្កឹះយកគ្រាប់ចេញ អាចទុកបានយូរ ។

- **ផ្លែស្វាយខ្ចី** : ចាប់មានពីខែកុម្ភៈរហូតដល់ខែមិថុនា ។ ប៉ុន្តែចាប់ពីទសវត្សឆ្នាំ១៩៦០ គេបានពូជស្វាយខុសរដូវដែលមានផ្លែអាចបរិភោគធ្វើជាម្ជូរបានស្ទើររាល់ថ្ងៃ ។

- **ផ្លែសណ្តាន់** : ចាប់ផ្តើមមានតិចតួចនៅខែមេសា ហើយកើនឡើងៗច្រើននៅខែកក្កដា ។ ផ្លែវាចាស់ឬទុំនោះ គេតែងចិតជាចំណិតៗហាលឱ្យស្ងួតទុកប្រើការបានយូរ រហូតជួបខួបវិញ ។ ម៉្យាងទៀតស្លឹកវាក៏គេបានប្រើជាម្ជូរសំរាប់បុកស្លដែរ ។

- **ផ្លែក្រសាំង** : អាចមានពីខែឧសភារហូតដល់ខែសីហា ។ ប្រសិនបើមានទុំចាស់ច្រើន គេតែងឆ្កៀលយកសាច់បុកក្រលុកលាយអំបិល ផ្អាប់ទុកប្រើការបានយូរ ។

ការប្រើម្ជូរនេះ ឃើញថានៅមានច្រើនទៀត ដូចជា : ស្លឹកថ្នឹង ផ្លែទ្រលឹងទឹង ផ្លែពង្រខ្ចី ស្លឹកម្កាក់ ស្លឹកក្រចកគោ....។ល។

❊ ❊ ❊



# ទំនៀមបុរសស្លៀកសំឡយ និងការឈរជាន់ថ្ម

**នៅ**ពេលរៀបពិធីអាពាហ៍ពិពាហ៍នៃប្រជារាស្ត្រខ្មែរ មានរៀបកម្មវិធីដែលប្រកបទៅដោយពិធីយ៉ាងច្រើន ។ ក្នុងនោះមានកម្មវិធីមួយ ដែលបុរសត្រូវស្លៀកសំពត់សំឡុយ គឺក្នុងពិធីសំពះផ្ទឹម ។ ពិធីនេះមានន័យសំខាន់ណាស់ គឺពេលនេះហើយដែលគេឱ្យកូនកម្លោះមកអង្គុយខាងស្តាំដៃកូនស្រីវិញ ។ ពេលនេះជាឱកាសបើកសិទ្ធិឱ្យទទួលយកនូវការរួមខ្នើយហើយស្ត្រីក៏ត្រូវមាននាទីជាមេផ្ទះ ។

ពិធីផ្ទឹមគ្នានេះ ក្នុងមង្គលការរបស់ជាតិសាសន៍ផ្សេងៗទៀតភាគច្រើនក៏មានរៀបចំដែរ តែគ្រាន់តែមានលក្ខណៈខុសគ្នាដោយការឈរក្នុងព្រះវិហារ នៅចំពោះមុខព្រះសង្ឃ(សាសនាគ្រីស្ត) ។ ការលុតជង្គង់សំពះចំពោះដូនតារបស់សាសន៍ចិន យួន...។ ដោយសារពិធីនេះមានអត្ថន័យខ្លាំងជាងគេដូច្នេះហើយ បានជាឪ-ម៉ែនាងវិះបង្គាប់ឱ្យព្រះបាទអង្គច័ន្ទរាមាធិបតី ស្លៀកសំពត់សំឡុយដូចបុរសចាមក្នុងពិធីផ្ទឹម ដែលកើតជាប្រពៃណីធ្វើតាមព្រះមហាក្សត្រអង្គនោះ តាំងពីពេលនោះរហូតដល់បច្ចុប្បន្ន ? ។

ក្នុងឯកសារមហាបុរសខ្មែរលេខ៤៧ មានចែងសេចក្តីជាអាទិថា :

ក្នុងគ.ស១៦៥៤ ព្រះអង្គច័ន្ទរាមាធិបតី ទ្រង់ភ្នកព្រះទ័យចង់យាងទៅក្រសាលនៅស្រុកទន្លេធំ ។ ទ្រង់គង់ក្នុងព្រះទីនាំងនាវា ចេញតាមផ្លូវទៅ

ក្រចេះ ។ នៅទីនោះ ចៅហ្វាយស្រុកគ្រប់ខេត្ត ដែលមានទីតាំងនៅជិតមាត់ទន្លេនោះ មូលមីរចូលមកក្រាបបង្គំគាល់ថ្វាយគ្រឿងបណ្ណាការផ្សេងៗជាច្រើន ហើយព្រះអង្គទ្រង់បញ្ជាឱ្យក្បួនហែរចៃវចូលទៅចតក្រុងស្រីសន្ធររួចស្ដេចឱ្យត្រឡប់ក្បួនហែរព្រះអង្គ មកកាន់ក្រុងឧត្តុង្គមានជ័យរាជធានីវិញ លុះយាងមកដល់ភូមិកំពង់ហ្លួងខាងត្បូងនោះ ព្រះអង្គឱ្យឈប់ព្រះទីនាំងនៅទីនោះ ហើយទ្រង់ក្រឡេកព្រះនេត្រទៅឃើញស្រីចាមម្នាក់ឈ្មោះនាងវ៉ះ ជាកូនចៃសុននិងនាងម៉ា(ព្រះវង្សចាម) ចុះមកដងទឹកនៅកំពង់នោះ មានរូបរាងល្អ ទាំងឫកកិរិយាក៏ឆើតឆាយទៀត ។ ទ្រង់ព្រះស្នេហាណាស់ ទើបទ្រង់ត្រាស់ឱ្យហៅពួកចៅចៃ(ព្រះវង្សស្ដេចចាម) មកសាកសួរ ។

ទ្រង់ត្រាស់ឱ្យពួកចៅចៃ គិតគូរសុំឱ្យបាននាងវ៉ះជាព្រះស្នំ ។ ចៅចៃនិងចៃសុនព្រមទាំងនាងម៉ា ក្រាបទូលថា បើទ្រង់ព្រមចូលសាសន៍ទើបថ្វាយបាន កុំថាតែនាងវ៉ះមួយនេះ ទោះ១០ឬ២០ក៏ថ្វាយតាមព្រះទ័យបានទាំងអស់ ។...

ដោយក្ដីពង្វក់ពីពួកចាម ព្រមដោយសេចក្ដីស្នេហាដ៏លើសលប់ចំពោះនាងវ៉ះពេក ព្រះអង្គចូលសាសន៍កាត់ចុងអង្គជាតិ ។ ឯស្បែកដែលកាត់ចុងអង្គជាតិនោះ បានយកទៅតំកល់ទុកក្នុងព្រះវិហារ ដុតខ្លឹមច័ន្ទក្រឹស្នាបូជា ហើយសន្មតព្រះវិហារនោះថា ព្រះវិហារឃ្លាំងស្បែក ។ ព្រោះពេលនោះក៏មាននាម៉ឺនយកគាប់យកគួរខ្លះ បានកាត់ចុងអង្គជាតិដែរ ។ ហេតុនេះបានជាហៅជាប់ថា ភូមិឃ្លាំងស្បែកជារៀងមក ។

នាងវ៉ះឡើងជាព្រះស្នំឯក តាំងនាមជាព្រះម៉ែនាងសាវ៉ះបុប្ផ មាននាទីត្រួតត្រាពួកក្សត្រីទាំងក្នុងនិងក្រៅព្រះរាជវាំង ។ ទ្រង់បានលើកមន្ត្រីចាមថ្វាឱ្យមានអំណាចកំហែងគំរាមលើមន្ត្រីខ្មែរ ។ ក្នុងនគរកើតចលាចល កើត



ចោរប្លន់ព្រោះទ្រង់រវល់តែប្រកិតប្រកៀកនឹងអ្នកម្នាងវ៉ះ ។...

ចំពោះការចូលសាសន៍នេះ មានបញ្ហាម៉្យាងទៀតគឺដោយសារព្រះអង្គមានរាជសត្រូវច្រើន គឺទ្រង់បានធ្វើគតព្រះបិតុលានិងព្រះជេដ្ឋារបស់ព្រះអង្គដែលជាអ្នកមានគុណ ក៏ព្រោះរាជសម្បត្តិ ។ ទ្រង់ចង់បានពួកចាមចុះចូលជួយគាំទ្រ ព្រោះទ្រង់បារម្ភចំពោះរាជសត្រូវដ៏ច្រើន ។...

ចំពោះប្រការដែលកូនកំលោះឡើងមកដល់លើផ្ទះកូនស្រី ដើម្បីអង្គុយយកពេលាសំពះផ្ទឹមដោយឈរជាន់លើថ្មនោះ ចាស់ៗឥឡូវនេះភាគច្រើនបានឱ្យន័យថា មកពីចង់ឱ្យកូនប្រុសពង្រឹងចិត្តឱ្យថិតក្នុងភាពរឹងប៉ឹង មិនឆេវឆាវ គឺប្រើចិត្តឱ្យធ្ងន់ហើយត្រជាក់ដូចថ្ម មុននឹងចូលទៅចាប់ដៃគូប្រចាំជីវិត តែក៏មានចាស់ៗមួយចំនួនទៀតបានឱ្យន័យផ្សេងទៅវិញ គឺលោករៀបរាប់ថា នេះជាទំនៀមធ្វើតាមព្រះបាទអង្គច័ន្ទអ៊ុំប្រាហ៊ុម[១] ដែលលោកថា ថ្វីត្បិតតែព្រះអង្គឈ្លក់វង្វេងមែន តែទ្រង់នៅនឹកឃើញដល់ឋានៈខ្លួនដែលជាព្រះមហាក្សត្រ ទ្រង់យល់ថាកុំបន្ទាបខ្លួនពេក នៅពេលឡើងមកដល់ផ្ទះខាងស្រីដែលមានពួកគេរង់ចាំត្រៀបត្រានោះ ទ្រង់ក៏បង្គាប់ឱ្យគេយកដុំថ្មមួយដុំមកដាក់លើផ្ទះ ដើម្បីឱ្យទ្រង់ឈរជាន់ឱ្យបានខ្ពស់ត្រដែតជាងពួកចាម មុននឹងក្រាបសំពះផ្ទឹម ។

❋ ❋ ❋

១-អ៊ុំប្រាហ៊ុមជាឈ្មោះដែលប្រជារាស្ត្រខ្មែរហៅ ដើម្បីកុំឱ្យច្រឡំ ព្រោះមានព្រះនាមស្ដេចខ្មែរសោយរាជ្យពីរព្រះអង្គទៀត គឺព្រះបាទអង្គច័ន្ទទី១សោយ រាជ្យក្នុងឆ្នាំ 1515-1555 ។ ព្រះបាទអង្គច័ន្ទទី២សោយរាជ្យក្នុងឆ្នាំ 1806- 1834 ។ ឯព្រះរាមាធិបតីច័ន្ទឬព្រះបុទុមរាជាទី២(អ៊ុំប្រាហ៊ុម) សោយរាជ្យ ក្នុងឆ្នាំ 1642-1658 ។

# សត្វដំរី

**ភ្ញាក**សាកស្តាយអាល័យចំពោះសត្វដំរី ដែលមានបរិមាណធ្លាក់ចុះខ្សត់ស្ទើរតែក្មួនខ្មែរបច្ចុប្បន្ននេះកម្របានឃើញផ្ទាល់ភ្នែក ។ បញ្ហាចំបងនេះកើតមានបានគឺដោយសារសង្គ្រាមរ៉ាំរ៉ៃ និងមនុស្សខ្មែរសម័យក្រោយខ្លះមិនបានយកចិត្តទុកដាក់ថែរក្សាកេរ្តិ៍ដូនតា ហើយថែមទាំងបំផ្លាញដោយចិត្តចេតនាដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។ ថ្វីត្បិតតែបច្ចុប្បន្នសត្វដំរីត្រូវបានហាមឃាត់ការបរបាញ់ ដោយប្រកាសរបស់ក្រសួងកសិកម្មរុក្ខា-ប្រមាញ់និងនេសាទ .និងជាប្រភេទសត្វត្រូវចុះក្នុងបញ្ជីក្រហម IVCN(GT) ជាប្រភេទសត្វកំពុងទទួលរងការគំរាមកំហែងលើពិភពលោក និងស្ថិតក្នុងតារាងឧបសម្ព័ន្ធទី១[(១)] របស់អនុសញ្ញា CITES[(២)] ។

សម័យដើម ប្រជារាស្ត្រខ្មែរចាត់ទុកសត្វដំរីជាសត្វមានសារៈសំខាន់ក្នុងការដឹកជញ្ជូនសំភារៈធំៗ ដូចជាការអូសឈើហ៊ុបជាដើម ។ ម៉្យាងទៀតដំរីក៏ជាមធ្យោបាយសំរាប់ធ្វើដំណើរផ្លូវឆ្ងាយលំបាក ឡើងភ្នំចុះភ្នំឆ្លងជ្រលងដងអូរដែរ ។ តាមពត៌មានរបស់លោកព្រឹទ្ធាចារ្យ **ឃឹម សាំង** អាយុជាង៨០ឆ្នាំ ជាវរៈតន្ត្រីករនៃព្រះរាជាណាចក្រកម្ពុជាបានមានប្រសាសន៍ថា : "ក្នុង

១-ការធ្វើពាណិជ្ជកម្មលើសំណាក ឬផ្នែកណាមួយរបស់វាអាចអនុញ្ញាតទៅ បានតែក្នុងលក្ខណៈពិសេសមួយគត់ ចំពោះប្រភេទរងការគំរាមកំហែងឈាន ទៅការផុតពូជ ។

២- CITES = Convention on International Trade in Endangered Species Flora and Fauna គឺអនុញ្ញាតស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិ លើប្រភេទជិតផុតពូជនៃសត្វនិងរុក្ខជាតិ ។



អំឡុងទសវត្សន៍ឆ្នាំ១៩៤០-១៩៥០ នៅខេត្តពោធិសាត់ កំពង់ធំ... ដែលជាខេត្តសំបូរដំរី ចៅហ្វាយស្រុកចេញមើលភូមិស្រុកឆ្ងាយៗ នៅប្រើជំនិះសត្វដំរីនៅឡើយទេ "។ តែឥឡូវនេះចំពោះបងប្អូននៅភូមិភាគឥសាន្ត ពិសេសខ្មែរព្នងខ្លះនៅខេត្តមណ្ឌលគិរី យើងសង្កេតឃើញថាសត្វដំរីនៅជាមធ្យោបាយដ៏សំខាន់ក្នុងការធ្វើដំណើរនៅឡើយដែរ ។ ពួកគេបានចាត់ទុកសត្វដំរីគឺជាទ្រព្យដ៏សំខាន់ ដែលមានភូមិខ្លះមានដំរីរហូតដល់០៥ក្បាល ។ តាមពត៌មានរបស់លោកតា **គ្រាក់ ញ៉ែក** អាយុជាង៨០ឆ្នាំ ជាព្រឹទ្ធចារ្យខ្មែរលើព្នងនៅភូមិពូលូង ឃុំរមនា ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី បានមានប្រសាសន៍ថា : "នៅសម័យអាណានិគមបារាំង ដែលច្បាំងជាមួយខ្មែរឥស្សរៈ ពួកបារាំងក៏បានប្រើដំរីជាមធ្យោបាយដឹកស្បៀងនិងគ្រឿងចំបាំងដែរ សម័យនោះក្នុងមួយឃុំមានដំរីយ៉ាងតិច៥០ក្បាល ហើយច្រើនរហូតដល់រាប់រយក្បាល" ។



ខ្មែរបុរាណមានជំនឿថា ដំរីជាសត្វមានឫទ្ធិ អាចព្យាបាលជំងឺផ្សេងៗបានដែរ ដូចជា :

-កុមារឈឺភ្នែក មាតាតែងឱ្យទ្រមាក់ដំរីបីកូនខ្លួនដើរចូលក្រោមពោះដំរី ចំនួនបីជុំ ។

-ពេលដំរីចូលភូមិ គេតែងឱ្យដំរីព្រួសទឹកប្រសិទ្ធិ ដើម្បីឱ្យបានសេចក្ដីសុខសប្បាយ[១] ។

-គេយកប្រែងកន្ទុយដំរី មកដោតក្នុងចិញ្ចៀនពាក់ដើម្បីឱ្យបានសេចក្ដីសុខ ។

-ការសុបិន្តឃើញសត្វដំរី គឺជាប្រផ្នូលល្អនៃការបង្អុរទឹកភ្លៀងក្នុងការធ្វើស្រែចំការ ។

នៅសម័យហ្វូណន់ មានទីក្រុងមួយឈ្មោះវ្យាធបុរៈ (ទីក្រុង = ទ្វាក់ < ទាក់ មានន័យថាប្រមាញ់ ទំនងដូចគ្នានឹងពាក្យខ្មែរទំនើបថា ទ្រមាក់)។ មុនសម័យអង្គរ មានសិលាចារឹកតែមួយគត់( K109គ.ស 655 ) ដែលនិយាយអំពីវ្យាធបុរៈ ។ សិលាចារឹកនោះស្ថិតនៅឆ្ងាយពីអង្គរបុរីនិងបាភ្នំ គឺឆ្ងាយទៅភាគខាងកើតខេត្តកំពង់ចាម ជិតក្រុងចាស់មួយឈ្មោះថា "បន្ទាយព្រៃនគរ" ។

នៅសម័យអង្គរ សត្វដំរីមានសារៈសំខាន់បំផុតក្នុងការធ្វើសឹកសង្គ្រាម វាយលុកដណ្ដើមជ័យជំនះចំពោះការការពារទឹកដី និងការបង្រួបបង្រួមជាតិជាស្ថាពរនៃចក្រភពអង្គរ ។ យើងបានដឹងតាមប្រវត្តិសាស្ត្រ ដែលចារពីសេចក្ដីក្លាហាននិងការឈ្លាសវៃរបស់ព្រះមហាក្សត្រ ក្នុងសម័យអង្គររុងរឿងដល់កំពូល ចំពោះការវាយបង្ក្រាបខ្មាំងសត្រូវព្រះអង្គ ដោយមានដំរីជាជំនួយដូចជា :

១-ដំរីអាចផឹកទឹករហូតដល់២០០លីត្រក្នុង១ថ្ងៃ (នៅកន្លែងសំបូរទឹក) ។





*រូបចម្លាក់ដំរី នៅព្រះលានដំរី*

-សិលាចារឹកបាងថាក បានដំណាលពីព្រះបាទសុរិយាវរ្ម័នទីពីរ ដែលកំពុងប្រយុទ្ធក្នុងសមរភូមិថា "ព្រះអង្គលោតផ្លោះពីលើព្រះទីនាំងគជេន្ទ្រទៅគង់លើក្បាលដំរីរបស់ព្រះរាជសត្រូវ ដែលទ្រង់ប្រហារជីវិតបង់ដីដូចជាគ្រុឌដែលស្ទុះទៅសង្គ្រប់សំលាប់ពស់នៅលើកំពូលភ្នំ" ។

-សិលាចារឹកនៃប្រាសាទព្រះខ័ន បានសរសើរព្រះបាទជ័យវរ្ម័នទី៧ថា "ព្រះអង្គបំបាក់ស្មារតីសត្រូវដែលបោះបង់ចោលការប្រយុទ្ធ ដោយសារឃើញព្រះអង្គទ្រង់គង់លើដំរី ហើយដៃកាន់សាស្ត្រាវុធយោធាគួរឱ្យរន្ធត់យ៉ាងខ្លាំង នោះសត្រូវបិទភ្នែកដោយចាញ់ចេស្ដា ដៃទាំងគូបីដូចជាពស់អស់ពិស ក៏ទំលាក់សរទាំងឡាយចោលភ្លាម រីឯព្រួញនិងស្នលំពែងដែលថាត្រូវបាញ់ឬចោលគ្រវែងក្នុងពេលមុននោះ ក៏ស្រាប់តែហាក់ដូចជាឈប់តាំងមួយរំពេចដែរ".... ។



រូបចម្លាក់នៅតាមប្រាសាទបុរាណ

នៅតាមរូបចំលាក់នៃប្រាសាទ ពិសេសប្រាសាទបាយ័ន យើងឃើញមេទ័ពជិះដំរី អង្គុយឬឈរដោយឥតបារម្ភខ្លាចធ្លាក់ ប្រយុទ្ធដោយស្ទាត់ជំនាញរួមជាមួយដំរីដែលជួយព្រេចវៃធសត្រូវ ។ ដំរីផ្ទុកទៅដោយកំហឹងជាមួយម្ចាស់គេ ព្រោះគេធ្លាប់ទទួលការហ្វឹកហាត់ឱ្យមានស្មារតីក្លាហាននិងប្រកបដោយភក្ដីភាពស្មោះត្រង់ចិត្តមួយថ្លើមមួយ តស៊ូប្ដូរស្លាប់រស់ជាមួយគ្នាត្រង់នេះគួរឱ្យន័យថា សត្វដំរីគឺជាយុទ្ធោបករណ៍មួយដ៏វិសេសវិសាលបំផុតក្នុងការធ្វើសឹកសង្គ្រាមដើម្បីវាយលុកដណ្ដើមជ័យជំនះ ។ អាចយោលលើព្រលឹងនេះហើយ បានជាប្រពៃណីនេះមានជីវិតចិតថេរមកដល់សម័យចតុ



មុខចំពោះការថែរក្សាសត្វដំរីក្នុងព្រះបរមរាជវាំង ថ្វីត្បិតតែសត្វដំរីលែងមាននាទីជាយុទ្ធោបករណ៍ក៏ដោយ ។ បច្ចុប្បន្ននេះយើងឃើញមានសល់អាគារផ្នែកខាងត្បូងជៀងខាងកើតនៃព្រះបរមរាជវាំង ដែលពាក្យសាមញ្ញហៅថា "**រោងដំរី**" ។ សត្វដំរីនេះគឺជាផ្នែកមួយនៃព្រះរាជទ្រព្យ ហើយក៏ត្រូវបានតំណាងឱ្យព្រលឹងជាតិខ្មែរ ក្នុងការប្រារព្ធពិធីបុណ្យឬជំនឿផ្សេងៗដែរ ។ អ្នកថែរក្សាដំរីសម័យនោះគឺជាបុគ្គលិករាជការមានយសសក្តិតាមលំដាប់ថ្នាក់តូចធំ ។ អ្នកមានសមត្ថភាពខ្ពស់ក្នុងជំនាញអាចបង្ក្រាបដំរីឱ្យលុះដោយពាក្យបង្គាប់បញ្ជា តែងត្រូវបានព្រះមហាក្សត្រប្រទានងារទៀតដូចជា "**ម្ហូថាន**" គឺជាចាស់ទុំឬជាអធិបតីលើអស់ហ្វូងដំរី ។

ក្នុងសម័យសាធារណរដ្ឋខ្មែរ ការថែរក្សាដំរីនៅមានជាធម្មតាដែរ ។ តែនៅសម័យសាធារណរដ្ឋប្រជាធិបតេយ្យនិងសម័យក្រោយៗ រហូតមកដល់សម័យរបបរាជានិយមកើតឡើងវិញ គេមិនឃើញមានការចិញ្ចឹមដំរីសំរាប់ព្រះរាជទ្រព្យឡើងវិញទេ ។



រូបចម្លាក់មេទ័ពជិះដំរីប្រយុទ្ធក្នុងសមរភូមិ

## ការទាក់ដំរី

ដោយសារសត្វដំរីមានអត្ថប្រយោជន៍យ៉ាងដូច្នេះហើយ បានជាមានអ្នកប្រមាញ់ដំរីហ៊ានតស៊ូការលំបាកប្តូរស្លាប់រស់ ។ ប៉ុន្តែគាត់មិនខ្លាចនោះក៏ព្រោះគាត់មានជំនឿទៅលើសមត្ថភាពរបស់គាត់ ដែលអាចចេញជាលទ្ធផលសំរាប់ចិញ្ចឹមជីវិត ។ ឈរលើសមត្ថភាពជាកត្តាមួយសមស្រប តែប្រការដែលសំខាន់ចាំបាច់គឺ **តំណម** ។ អ្នកទាំងនោះគេមានជំនឿច្រើនណាស់ដែលមានលក្ខណៈផ្សេងៗក្នុងការតម ។ តំណមដែលត្រូវតមមិនមានចំពោះតែរូបខ្លួនគេផ្ទាល់ទេ តែត្រូវមានភរិយាចូលរួមដែរ ។ ការចូលរួមតមរបស់ភរិយានេះ ជាប្រការចាំបាច់និងសំខាន់ខ្លាំងណាស់ ព្រោះវាអាចមានគ្រោះថ្នាក់ដល់ស្លាប់ ឬទទួលជោគជ័យសំរេចលទ្ធផល ។



ការប្រើប្រាស់ដំរីរបស់អ្នកស្រុកព្រៃភ្នំ



## តំណម

ប្រការត្រូវជៀសវាងរបស់ភរិយានៅពេលប្តីចេញទៅទាក់ដំរីមាន :

-មិនត្រូវរើជជុះកន្ទេលខ្នើយរួមដំណេក

-មិនត្រូវឱ្យនរណាទៅជិតប៉ះកន្ទេលខ្នើយរួមដំណេក

-មិនត្រូវតងរែកលើឆ្នាំង

-មិនត្រូវសិតសក់

-មិនត្រូវជេរប្រមាថអ្នកដទៃ ទោះជាកូនខ្លួនឯងក៏ដោយ

-មិនត្រូវស្រែកឆ្លងឆ្លើយ ទោះមានភ្ញៀវស្រែកហៅក្តីគឺត្រូវចេញទៅទទួលហើយនិយាយតួរសមដោយសម្លេងល្មម ។

-មិនត្រូវបើកគំរបឆ្នាំងនៅពេលបាយមិនទាន់ឆ្អិន(ទាក់មិនបាន)

-មិនត្រូវលាបសក់នឹងប្រេងដូង ព្រោះព្រំត្រដែលធ្វើពីស្បែកក្របីសំរាប់ទាក់ដំរីនោះ វាអាចនាំឱ្យរអិលរបូតដំរីរើបំរះចេញវិញបាន ។ ប៉ុន្តែមានអ្នកខ្លះថារហូតដល់ទទួលគ្រោះថ្នាក់ទៀត ដោយគ្រាន់តែប្រេងដូងហៀរស្រក់លើក្បាល[១] ។

-នៅពេលព្រឹកនិងពេលរសៀល ត្រូវនាំកូនដើរលេងទាក់បង្គួយ ដោយត្រូវប្រឹងប្រែងទាក់ឱ្យបាន ព្រោះការទាក់បង្គួយបាន វាជាប្រផ្នូលល្អអាចឱ្យប្តីទាក់ដំរីបានដែរ ។ ការដើរលេងនៅពេលព្រឹកនិងរសៀលនេះមានន័យស្របទៅនឹងសត្វដំរី ដែលតែងបណ្តើរកូនដើរលេងចេញវាលនៅពេលត្រជាក់ដែរ ។

នៅមានតំណមផ្សេងៗដោយឡែកៗទៀត ដែលអ្នកទាក់ដំរីបានប្រកាន់

១-សូមអានអត្ថបទបន្តខាងក្រោយ

យកទំលាប់ត្រូវរៀងៗខ្លួន ។ ចំណែកតំណមចំពោះប្ដីដែលជាសាមីខ្លួនទៅទាក់នោះ មិនមានអ្វីក្រៅពីជៀសវាងជេរប្រទេចប៉ុណ្ណោះទេ ។ ឯការសំខាន់នោះ គឺត្រូវពឹងលើសមត្ថភាពនៃការវាងវៃនិងបទពិសោធន៍នានា ។

## មុនពេលទៅទាក់

មុនពេលចេញទៅទាក់ គេត្រូវប្រមូលគ្នាមករៀបពិធីសែនព្រេនចំពោះគ្រូធ្លាក់ ក៏ដូចជាការអញ្ជើញអស់លោកទាំងនោះឱ្យមកចូលរួមដំណើរទៅជួយទាក់ដែរ ។

វណ្ណាប់ដែលត្រូវរៀបចំនោះ មានតែបាយសីមួយថ្នាក់(មួយតួ) ស្លាធម៌(មួយតួ) ម្លូ ស្លា បារី ហើយអុជទៀនធូបដើម្បីប្រកាសអញ្ជើញមកពិសាភោជនាហារ មានបាយម្ហូបចំអាប់បង្អែមនិងផ្លែឈើផ្សេងៗតាមដែលអាចមាន ។ ក្នុងឱកាសនេះ គេត្រូវលេងភ្លេងថ្វាយនូវបទសុរិន្ទ្រខ្នងភ្នំដែលមានន័យថានិមន្តគ្រូ ។ ភ្លេងដែលលេងនោះមិនមានឧបករណ៍ច្រើនទេ គឺមានតែមួយមុខ ដោយជូនគេយកប៉ីពក ឬភ្លុយ តែបើគ្មានគេអាចយកស្លឹកជំនួស ។ ប៉ុន្តែ ស្លឹកមានតែបីសម្លេងមិនសូវពិរោះ ។

ទំនុកច្រៀងមានដូចតទៅ :

-អើយសុំនិមន្តគ្រូ និមន្តគ្រូធំ ចុះពីកំពូលភ្នំ ចាក់ព្រៃពេញវាល ។

-ចាក់ទាំងគុម្ពព្រេច ចាក់ទាំងគុម្ពព្រាល ចាក់ព្រៃពេញវាល ដោយសារគ្រូនិមន្តមក ។

ជាបន្តមកទៀតគេលេងបទបណ្ដាំ ដែលមានន័យជាពាក្យផ្ដែផ្ដាំនូវតំណមផ្សេងៗចំពោះភរិយា ដើម្បីពង្រឹងនូវមនោសញ្ចេតនារវាងគ្នាទៅវិញទៅមក និងដើម្បីសង្កត់ការចងចាំមិនឱ្យមានការភ្លាំងភ្លាត់ ។



-អើយបងឡើងក្បាលធ្លាក់[១] ជើងចាក់ទន្ទឹង[២] អូនកុំសង្រេងថ្ងៃអើយបងវិលវិញទេ ។

-បើស្រីស្ងួទំពាំង អូនកុំបង់ខ្សង ប្រយ័ត្នវាខុសតំណមបង បងទៅទាក់ក្បាត់[៣] ។

-បណ្ដាំបងផ្ដាំនេះ តឹងទៀងណាស់ តាំងពីក្មេងទល់ចាស់ គ្មានល្បៀងទឹកកុំឱ្យងូត គូថកុំឱ្យលាង តែលាងកាលណា សត្វធ្វើទុក្ខបង ។

នៅពេលទៅដល់ព្រៃ គេតែងនាំគ្នាស្រែកច្រៀងនូវបទបន្ទីព្រៃវាលដើម្បីកំដរបរិយាកាស ។ ឧបករណ៍ដែលផ្លុំនោះមាន ប៉ីពក ឬភ្លុយ ឬផ្លុនគេកាច់ស្លឹកឈើផ្លុំ ។ ចំពោះទំនុកគេច្រើនលើកឡើងពីទេសភាពជុំវិញព្រៃភ្នំ មានជាអាទិដូចតទៅ :

-អើយឡើងភ្នំចុះភ្នំ ព្រះគុណអើយចុះភ្នំ ថ្មដាអើយធំៗ ឱ ! រលំបែកផ្សែង... ។

## ឧបករណ៍សំរាប់ទាក់ដំរី

**១-ប្រគាំ** : ជាខ្សែពួរព្រ័ត្រធ្វើពីស្បែកក្របីយ៉ាងធំ វេញជាបីផ្លូងទំហំអង្កត់ផ្ចិត៣៥មីលីម៉ែត្រ មានប្រវែងយ៉ាងតិច១២ម៉ែត្រ ដើម្បីងាយស្រួលអូសបន្ទាយ ។ រីឯចុងម្ខាងគេវេញឱ្យមានរង្វង់ក្រវិល ។

---

១-ក្បាលធ្លាក់ : ក្បាលដំរី ដែលជាជំនួយក្នុងការជួយទាក់

២-ទន្ទឹង : ខ្សែប្រឡៅកដែលគេចងព័ទ្ធជុំវិញក

៣-ទៅទាក់ក្បាត់ : ទៅទាក់ដំរី តែគេឧបកិច្ចឱ្យមានភាពតូចនិងគ្មានថាមពល



*ប្រកាំ ប្រើក្នុងការទាក់ដំរី*

**២.ជនកាចាមមួយដើម** : ជាឫស្សីពីងពង់សំរាប់ដាក់អែបប្រកាំឱ្យរឹងត្រង់ និងសំរាប់ជួយរុញឆ្កឹះជើងកូនដំរី ឱ្យដើរលើកជើងខ្ពស់។ ដើម្បីងាយស្រួល ក្នុងការសិកចូលក្នុងក្រវិលប្រកាំ ។

**៣.ខ្សែព្រ័ត្រ** : ជាខ្សែព្រ័ត្រធ្វើពីស្បែកក្របីដែរ តែតូចជាងប្រកាំបន្តិច មានទំហំអង្កត់ផ្ចិត២៥មីលីម៉ែត្រ មានប្រវែងប្រហែល១៥ម៉ែត្រ ។ ខ្សែនេះ សំរាប់ចងកកូនដំរីដែលទាក់បានហើយនោះភ្ជាប់មកនឹងមេធ្នាក់ ។

**៤.ស្នែង** : ធ្វើពីស្នែងក្របី សំរាប់ផ្លុំប្រកួកហៅគ្នាមកហូបបាយឬសំរាក និងពិសេសប្រកួកហៅគ្នាឱ្យមកជួយគ្នាជាបន្ទាន់ នៅពេលមានអាសន្ន ។

**៥.រយាង** : សំរាប់ចងខ្នងដំរី ក្នុងការជួយទ្រមាក់ឱ្យឈរមានលំនឹងកុំឱ្យ រអិលឬងាយហក់ទៅលើក្បាលឬមកលើខ្នងវិញ ហើយបង្វិលដោយគោងខ្សែ រយាងមកក្រោមពោះ ដើម្បីគេចពីមេដំរីគក់ ។





*ស្នែងទាក់ដំរី*

**៦.កង្វេរ** : សំរាប់ផ្ដក់ទាញត្រចៀកដំរីឱ្យស្ដាប់តាមបញ្ជា ឯខាង សំរាប់ចុចក្បាលឬខ្នងដំរីឱ្យឈឺចាប់ស្ដាប់តាមបញ្ជាដែរ ។ ក្បាលកង្វេរធ្វើពី ដែកស្រួចចុងប្រវែងកន្លះម៉ែត្រ ឯដងធ្វើពីឈើដែលគេឈូសលុញឱ្យមូល សិកភ្ជាប់ទៅនឹងក្បាលកង្វេរនោះ មានប្រវែងប្រហែល១ម៉ែត្រ ។



*កង្វេរ*

**៧.ទន្លីងក** : ជាខ្សែព្រ័ត្រធ្វើពីស្បែកក្របី សំរាប់ចងកធ្នាក់ប្រៀបដូច ប្រឡៅកផ្ដៃ សំរាប់ឱ្យទ្រមាក់ជាន់ចុះឡើងជិះដំរីបានយ៉ាងងាយ ខុសពីទន្ទឹង សំរាប់ចងជើងដំរីទាំងពីរនៅពេលវាចុះប្រេង ។

**៨.ជន្លាប់ក្រមួន** : គ្រូដែលធ្លាប់ទាក់ចំណាន។ ដល់ពេលចាស់មិនអាច ចេញទៅទាក់បាន ក៏នៅចេះអួមអាបមន្តអាគមប្រសិទ្ធិក្រមួនដាក់ជន្ទាប់

សំរាប់ឱ្យទ្រមាក់លាបក្បាលនិងខ្លួនប្រាណ ហើយប្លុងស្នូងប្រកាសហៅគ្រូស្មិល ឱ្យមកសណ្ឋិតជួយនៅពេលចេញពីជំរុំទៅទាក់ដំរី ។

**៩~ឆ្នាក់ :** គឺជាដំរីឈ្មោលស្លូវធំគ្មានភ្លុកទេ មានតែថែ សំរាប់ទ្រមាក់ជិះទៅទាក់ ហើយជំនួយយ៉ាងសំខាន់ក្នុងការជួយទាក់ ។

## វិធីទាក់

គេច្រើនទៅទាក់ដំរីនៅរដូវវស្សា ព្រោះនៅរដូវប្រាំងដំរីច្រើននាំគ្នាទាំងហ្វូងៗចុះទៅទំនាបតាមដងទន្លេតាមព្រៃរនាម ដែលមានដុះស្នាប់វិមរវាមមិនងាយទាក់ជើងដំរីបានទេ ។ បើនៅរដូវវស្សាវាច្រើនដើរក្នុងព្រៃស្រោងក្រោមដើមឈើដុះខ្ពស់ៗបណ្តើរកូនរកចំណីអាហារ ឬដើរលេងឡើងភ្នំចុះភ្នំតាមមាត់ស្ទឹងឬដងជ្រោះ ។ ម៉្យាងទៀតទ្រមាក់មានការងាយស្រួលគេចវាងចុះឡើងតាមដើមឈើទៀត ។ អ្នកមានដំរីទៅទាក់ម្តងៗមានគ្នាយ៉ាងតិច១០នាក់ ប្រកបដោយឧបករណ៍គ្រប់គ្នាដូចបានជំរាបជូនខាងលើ ។ ពេលទៅដល់ព្រៃ គេនាំគ្នារៀបចំជំរុំសំរាប់ស្នាក់នៅ ដោយកាប់មែកឈើប្រក់ជាដំបូល ហើយសំរាកនៅលើស្លឹកឈើផ្ទាល់ដីទៀត ។ គេមិនខ្លាចសត្វល្អិតទិចឬខាំទេ ព្រោះគេមានថ្នាំបែបបុរាណឬមន្តអាគមស្តោះផ្លុំ ។ ចំពោះសត្វធំៗក៏ពុំហ៊ានមកយាយីគេដែរ ព្រោះគេមានមេឆ្នាក់ធំៗច្រើន ដែលធ្វើឱ្យសត្វសាហាវទាំងអស់មិនហ៊ានមកជិត ។ ម៉្យាងទៀតសត្វទាំងនោះខ្លាចភ្នក់ភ្លើងដែលគេបានបំពក់ផង ។

គេបែកហ្វូងគ្នាទៅទាក់នៅពេលព្រឹកព្រហាម និងថ្ងៃរសៀលជាពេលត្រជាក់ គឺជាពេលដំរីច្រើនបណ្តើរកូនដើរលេង ។ គេចែកជាក្រុមចំនួនពីរទៅបីនាក់ ដោយមិនរាប់បញ្ចូលអ្នកចេញទៅតាមហាត់រៀនមើលស្នូនទាក់ដំរី:ទ ។ នៅពេលដែលឃើញមេដំរីបណ្តើរកូន គេញាក់និងយកកង្វេរទា



ត្រចៀកឆ្នាក់ឱ្យដើរទៅជិតហ្វូងដំរី ។ ដំរីបែកហ្វូងរត់យក្សូចខ្លួនរៀងៗខ្លួន។ ប៉ុន្តែមេដំរីបណ្តើរកូនច្រើនរត់មិនរួចព្រោះមនោសញ្ចេតនាចំពោះកូន ម៉្យាងទៀតកូននោះច្រើនរត់ឆ្វេឆ្វាតែក្រោមពោះមេទៀត ។ ពេលនោះហ្មអង្រន់និងញាក់ឆ្នាក់ឱ្យទៅតក់មេដំរី ។ ឯទ្រមាក់ឈរនៅលើខ្នងឬលើ-កដំរី ដៃកាន់ប្រកាំនិងដងកាចាមផ្តោបគ្នារុញជើងកូនដំរីឱ្យលើកជើងផុតពីដី ដើម្បីស៊កក្រវិលប្រកាំ ។ នៅពេលជើងស៊កចូលក្នុងរង្វង់ក្រវិលប្រកាំបានហើយ គេទាញរូតរង្វង់ក្រវិលឱ្យតឹងណែនជាប់ជើងកូនដំរី ហើយអូសទាញឱ្យចេញពីក្រោមពោះមេ ។ ពេលនោះឆ្នាក់តក់មេដំរីយ៉ាងធូន់ដៃ ឯទ្រមាក់វិញក៏ត្រូវទាញកូនពង្វាងបញ្ចេរពីមេឱ្យបានដែរ ។ ឆ្នាក់តក់មេយកពីឈ្នះដៃ លុះត្រាតែមេលែងហ៊ានមកជិតកូន ហើយឈរយំសំរក់ទឹកភ្នែករហាម ។ កូនដំរីដែលទាក់បាន ទ្រមាក់ត្រូវទាញឱ្យដើរតាម ឃ្លាតឆ្ងាយទៅៗផុតពីភ្នែកមេនៅពេលលែងឃើញមេហើយ ទ្រមាក់យកខ្សែព្ជួរព្រ័ត្រម្ខាងមកចងកកូនដំរីហើយម្ខាងទៀតចងកឆ្នាក់ ។ កូនដំរីដើរតាមឆ្នាក់រហូតដល់ភូមិស្រុក ។ តែគេចងវាទុកនឹងដើមឈើគ្រាក់ៗនៅជំរុំ ក្នុងពេលគេចេញទៅជួយទាក់គ្នាទៀត ។ នៅពេលគេចេញទៅទាក់អស់ មានមេដំរីខ្លះបានលួចមកបបោសអង្អែលកូនហើយយំទឹកភ្នែករហាម វាសំរេចចិត្តដើរទៅតាមហ្វូងតាមស្លូវធំៗជាមេហ្វូង នៅពេលគេនាំកូនចេញពីជំរុំអស់ បានសេចក្តីថាវាលែងឃើញកូនទៀតហើយ ។ ប៉ុន្តែមានមេខ្លះមានកម្លាំងសាហាវណាស់ មិនងាយចុះចាញ់ភ្លាមៗទេ ។ វានៅតស៊ូប្រយុទ្ធស្ទើរតែឆ្នាក់ទប់ទល់មិនបាន ដែលអាចបណ្តាលឱ្យទ្រមាក់ទទួលគ្រោះថ្នាក់បាន គឺវាដេញព្រេចឬតក់ទ្រមាក់វិញ ។ ពេលនោះទ្រមាក់ផ្លុំស្នែងប្រកាសភាពអាសន្ន ឱ្យទ្រមាក់ផ្សេងទៀតបានដឹងហើយមកជួយ ។ ទ្រមាក់ដែលមកជួយត្រូវពន្យុសឆ្នាក់របស់ខ្លួន ឱ្យជួយ

គក់មេដំរីនោះលុះត្រាតែចុះចាញ់ ដើរចេញលែងហ៊ានមកតាមកូន ។ ជួន ទ្រមាក់ផ្សេងទៀតមកមិនទាន់ ទ្រមាក់ដែលប្រកួតប្រកាសហៅគេឱ្យមកជួយ នោះ ត្រូវទទួលគ្រោះថ្នាក់ដោយសារមេគក់ក៏មានដែរ ។ ប៉ុន្តែការស្លាប់ ដោយសារការទាក់ដំរីនោះមិនសូវមានទេ ព្រោះមុននឹងហ៊ានចេញទាក់ គេ សុទ្ធតែបានទទួលការអនុវត្តន៍ ដោយដើរតាមមើលមេរៀនពីទ្រមាក់ចំណោទ។ អ្នកដែលដើរតាមសិក្សានោះ ក៏មានប្រដាប់ប្រដាផ្សេងៗនិងមេធ្មាក់ដូច ទ្រមាក់ទាក់ដំរីដែរ ។ គេនិយាយថាការស្លាប់ច្រើនកើតមានពីការខុសតំណម ផ្សេងៗ ពិសេសប្រពន្ធមិនកាន់តំណមបានត្រឹមត្រូវ ។



ការទាក់ដំរី

គេទៅទាក់អស់រយៈពេលពីពីរទៅបីខែ ។ ទាក់បានពីបួនទៅប្រាំកូន ដំរីក្នុងចំណោម១០នាក់ ។ ទោះជាទាក់បានហើយក៏ដោយ ក៏គេត្រូវនាំគ្នា



ទៅទៀតដើម្បីជួយអ្នកដែលមិនទាន់ទាក់បាន ។ គេមានស្មារតីសាមគ្គីភាព ណាស់ គឺគេត្រូវតែជួយគ្នាឱ្យបានគ្រប់ មិនអាចឱ្យនរណាម្នាក់ឥតបានឡើយ

## ការផ្សាំងនិងការចិញ្ចឹម

នៅពេលមកដល់ភូមិស្រុក គេយកកូនដំរីដែលទាក់បាននោះទៅចង នឹងដើមឈើធំៗ។ ជារៀងរាល់ថ្ងៃគេតែងតែដងទឹកមកមុជឱ្យដោយបបោស អង្អែលថ្នមៗ ដោយឱ្យអំពៅ ស្មៅ ចេក ស៊ី ហើយប្រើភាសាមនុស្សដែរ ដូចជាឱ្យរៀនសំពះ ក្រាប ដើរ,,,។ គេយកកូនដំរីទៅឃ្វាលឱ្យស៊ីស្មៅដូច ឃ្វាលគោដែរ ។ ប៉ុន្តែដំរីចេះជាងគោ នៅពេលវាដើរចុះឡើងប្រទាក់ខ្សែ ចងនោះ វាចេះដើរត្រឡប់វិលឱ្យមកតាមលំនាំដើមវិញ ។

ទ្រមាក់មានជំនឿថាកូនដំរីដែលទាក់បានមកនោះ សុទ្ធតែមានម្រេញ គង្វាលមកតាមជួយថែរក្សា ។ ដូច្នេះគេតែងរៀបសង្រែកចងព្យួរដោយដាក់ បាយសម្លឱ្យស៊ីរាល់ថ្ងៃ ហើយមានដាក់អង្គញ់ឱ្យលេងទៀតដើម្បីឱ្យពួកនោះ សប្បាយចិត្ត ជួយមើលថែរក្សាកុំឱ្យដំរីនោះវង្វេងដើរបាត់ពីផ្ទះ ឬមានជំងឺ មកបៀតបៀន ។ នៅពេលដំរីធំល្មមសាំងហើយ គឺមិនអាចទៅរស់ឯព្រៃ បាន ទ្រមាក់ចាប់បង្ហាត់ដោយវិធីចាប់បង្ខំ និងគំរាមកំហែងដើម្បីឱ្យវាខ្លប ខ្លាច ។ គេយកកង្វេរចុចសាច់រហូតដល់ធ្លុះសាច់ឬកាត់ស្នឹកត្រចៀករហូត ដល់រហែក ។ បើគេធ្លាប់ចុចឬកាប់សាច់កន្លែងណាហើយ គេត្រូវកាប់ កន្លែងដដែលៗហ្នឹង ព្រោះកន្លែងដដែលវាមិនទាន់សះជា អាចបណ្តាលឱ្យ វាមានការឈឺចាប់ជាងកន្លែងមិនសូវត្រូវរបួស ។ សាច់ដំរីឆាប់សះជា ណាស់ ព្រោះស្បែកវាមានខ្លាញ់សំរាប់ផ្សះ ឬជួនណាវាយកប្រមោយកេវ ចូកដីមកបិទមុខរបួស ក៏ជាដោយឯកឯងដែរ ។

នៅពេលវាចុះប្រេង បានសេចក្តីថាវាចង់ពាក់ញីតែគ្មានញីនោះទ្រមាក់

ត្រូវបង្អត់ចំណីវាមួយថ្ងៃឬពីរថ្ងៃ ឬរហូតដល់មួយសប្ដាហ៍ តាមការជាក់ស្ដែង ។ គេអាចយល់ដឹងដោយសារវាទំលាក់ប្រមោយញ្ញើងៗ ដែលគេហៅថា "**ទំលាក់បំពង់** " ។ ម៉្យាងទៀតនៅពេលនេះ គេឃើញមានប្រេងហូរចេញពីរន្ធមួយនៅចន្លោះរន្ធត្រចៀកនិងភ្នែក ។ វាតែងគោរពស្ដាប់បង្គាប់ទ្រមាក់គ្រប់ពេល តែវាធ្វើឫកក្រអឺតមិនស្ដាប់បញ្ជានៅពេលវាចង់ចុះប្រេង ។ វាច្រើនចុះប្រេងនៅរដូវប្រាំង ហើយចំពេលត្រជាក់ ។ ទ្រមាក់តែងប្រុងប្រយ័ត្ន ដោយចងវានឹងទន្ទឹងជើងយ៉ាងមាំ ។ ប្រសិនបើដាច់ទន្ទឹង ទ្រមាក់ត្រូវរត់ដេញតាមកាប់វាទាល់តែចុះញ៉ម ។ គេមិនអាចអាណិតបានទេព្រោះនឹងអាចមានគ្រោះថ្នាក់ដល់ជីវិតអ្នកដទៃ គឺវាដេញព្រេចមនុស្សណាដែលវាប្រទះ វាគាស់រំលើងផ្ទះសំបែង រថយន្ត បោចបាចដើមឈើ...។ ជួនពេលខ្លះវាលែងខ្លាចទ្រមាក់ម្ចាស់វាផង ពេលនោះគេត្រូវរកទ្រមាក់ដែលធ្លាប់ចិញ្ចឹមដំរីជាច្រើន ហើយមានបទពិសោធន៍ខ្ពស់ព្រមទាំងវាងវៃរហ័សរហួន ដោយមានចិត្តកាចឥតត្រាប្រណី ។ គេកាប់វាដោយពូថៅកប់ផ្លែ គឺកាប់ទាល់តែបាក់ស្បាតចុះទ្រោម ហើយចាប់ចងទន្ទឹងជាថ្មីបង្គាប់ឱ្យត្រឡប់មកកាន់ផ្ទះវិញ ។ វាចុះចាញ់ដោយសារឈឺចាប់ព្រមទាំងជើងជាប់ទន្ទឹង ។ តែវាសុខចិត្តវិលត្រឡប់មកកាន់ផ្ទះវិញនិងសំរក់ទឹកភ្នែក ដោយសូរសៀងស្នែង ឬប៉ីពកដែលហួបានផ្លុំដែរ ។ សំនៀងនេះវាធ្លាប់បានឮ និងធ្លាប់ធ្វើឱ្យវាបាក់ស្បាត កាលពីអតីតកាលនៅក្នុងព្រៃ ។ ទ្រមាក់ដំរីបានបញ្ជាក់ថាសំនៀងស្នែងឬប៉ីពកមានឥទ្ធិពលមែន តែក៏ត្រូវលាបក្រមួនស្នេហ៍សូត្រមន្តអាគមគាថាជាមុនសិន ដើម្បីបន្ទន់ចិត្តវា ។ មន្តអាគមនេះគេហៅថា "**ស្នេហ៍ស្និល** "។

មូលហេតុខ្លះញី ព្រោះគេមិនបានយកញីដែលមានឈ្មោលជាគូ ឱ្យដំរី



ចុះប្រេងផ្សេងពាក់បានទេ ។ សត្វនេះប្រច័ណ្ឌណាស់ ព្រោះបើពេលវាដឹងថា គេយកញីរបស់វាទៅឱ្យឈ្មោលផ្សេងៗពាក់នោះ វានឹងបុកដោយភ្លុកឬខ្នាយទាល់តែញីស្លាប់ ។ ប៉ុន្តែចំពោះបងប្អូនខ្មែរលើព្នង ដែលមានដំរីច្រើននោះ គេក៏មិនឱ្យវាពាក់គ្នាដែរ ព្រោះគេមានជំនឿថា កាលណាមានដំរីកើតកូនក្នុងស្រុកភូមិនោះនឹងកើតមានឧបទ្រព្យចង្រៃ ព្រោះដំរីជាសត្វព្រៃ។ ប្រសិនបើមានការជ្រុលជ្រួស គេត្រូវរៀបចំពិធីលៀងលាស(១) ដែលចំណាយប្រាក់កាស់និងកាប់គោក្របីសែនច្រើនណាស់ ទើបអ្នកភូមិបានសេចក្ដីសុខ។

## ការរស់នៅរបស់ទ្រមាក់ និងក្រុមគ្រួសារ

ចំពោះការរស់នៅជាធម្មតា មិនមានតំណមអ្វីទេ គឺប្រព្រឹត្តជាធម្មតាតាមទំលាប់ ។ ប៉ុន្តែជារៀងរាល់ថ្ងៃ គេតែងអុជធូបនៅកន្លែងអាសនះថ្វាយគ្រូធ្នាក់ ឬគ្រូស្និលរបស់គេ ដែលមានបាយសីមួយថ្នាក់មួយគូ ស្លាធម៌មួយគូ និងជន្ទាប់ក្រមួន ។ គេតែងដាក់បាយទឹកជារៀងរាល់ថ្ងៃ ហើយរៀបចំធំដុំនៅថ្ងៃចូលឆ្នាំខ្មែរ ។ ក្នុងគ្រួសារទ្រមាក់មួយៗ សុទ្ធតែមានដំរីសំរាប់បំរើការ ។ អ្នកខ្លះមានរហូតដល់ចែកកូនចៅគ្រប់ៗគ្នាទៀត ។ បើនៅសល់គេលក់ដូរចែកចាយដល់គ្រួសារដែលមិនចេះទាក់ ។

ក្រៅពីរបរទាក់ដំរី គេប្រកបរបរធ្វើស្រែចំការដូចអ្នកដទៃដែរ ។ មានអ្នកខ្លះមានតួនាទីក្នុងរាជការ ដូចជាមេឃុំ ចៅហ្វាយស្រុកដែរ ។ ប៉ុន្តែបងប្អូនខ្មែរលើព្នងនៅខេត្តមណ្ឌលគីរី អ្នកមានជំនាញទាក់ដំរីយ៉ាងចំណាន គេ

១-លៀងលាស : ពាក្យនេះអ្នកស្រុកមណ្ឌលគីរីបានស្គាល់ច្បាស់ គឺមានន័យថាជាការរៀបចំពិធីជប់លៀងចំពោះវត្ថុសក្តិសិទ្ធិនៃបងប្អូនខ្មែរលើព្នង ដើម្បីអង្វរករបន់ស្រន់សុំសេចក្ដីសុខសប្បាយ ។

មិនធ្វើស្រែចំការទេ ។ អ្នកស្ទាត់អាចទាក់ដំរីបានរហូតដល់១០០គេហៅថាគ្រូធំ ។ ចំពោះគ្រូមធ្យម គឺទើបតែទាក់បាន១៥ទៅ២០ក្បាលប៉ុណ្ណោះ ។ អ្នកមានរបរទាក់ដំរី នៅពេលទាក់បានគេអាចយកទៅលក់ដូរដោយគិតជាមាស ដូចជាដំរីកំពស់៤ហត្ថ តំលៃមាស៤ដំឡឹងជាដើម ។...

## ជំនឿក្នុងរឿងទាក់ដំរី

គ្រូដែលជួយទាក់ដំរីជាគ្រូអរូប កាន់លើគ្រូដែលចេះរបៀនមន្តអាគមស្និល សំរាប់ប្រសិទ្ធីដំរីនិងអ្នកទាក់ មុនពេលចេញទៅទាក់ដំរី ។ មន្តអាគមស្និល អាចធ្វើឱ្យមនុស្សមានកំលាំងខ្លាំងលុបមានលើសប្រក្រតី។ ពេលគេខឹងគេអាចខាំត្បាល់បុកគ្រៀងគ្រវែងទៅបានឆ្ងាយ ឬអាចខាំបានកែវស៊ីបាន ។ ក្នុងឆ្នាំ១៩៨១-៨២ យើងខ្ញុំធ្លាប់បានឃើញផ្ទាល់កូនលោក យឹម សាំង ឈ្មោះ **យឹម សេន** ខាំកែវទំពារស៊ីបាន ។

តាមការអធិប្បាយរបស់លោក **យឹម សាំង** ជាគ្រូគន្ថ្រីបុរាណកាន់ឧបករណ៍ផ្លុំ នៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានមានប្រសាសន៍ដូចតទៅ :

ជនជាតិខ្មែរលើព័រ រស់នៅក្នុងខេត្តពោធិសាត់ ច្រើនមានជំនាញយ៉ាងចំណានក្នុងការទាក់ដំរី ព្រោះខេត្តនេះសំបូរទៅដោយដំរី ។ លោកមានបងធម៌ជាជនជាតិខ្មែរលើព័រ បានប្រទះភាពជាក់ស្តែងនូវឧប្បត្តិហេតុមួយគឺ :

មានប្រពន្ធអ្នកទាក់ដំរីម្នាក់ បានទទួលទានដំណេកក្រោមហ៊ឹងតម្កល់គ្រឿងសក្ការៈបូជាសំរាប់គ្រូស្និល ដែលមានដាក់ផន្ទាប់ក្រមួនស្វលាយជាមួយប្រេងដូង ។ នៅពេលក្តៅក្រមួននោះបានរលាយហូរប្រេងដូងស្រក់លើក្បាល ស្រាប់តែនាងភរិយានោះស្ទុះងើបប្រកបដោយកំលាំងដូចដំរីសាហើយរត់ចូលព្រៃ ។ នាងនោះចេះដើរជើងបួន ផ្ទារពោះឡើងទៅលើ ដើរតាមហ្វូងខ្លា ដោយដោះសំលៀកបំពាក់ចេញអស់ ហើយលែងចេះនិយាយទៀត ។



អ្នកស្រុកបានដឹងនាំគ្នារត់ទៅព្រៃ ដើម្បីហៅប្តីឱ្យមករៀបចំបួងសួងសុំខមាទោសគ្រូ ។ ប៉ុន្តែហួសរយៈពេល៧ថ្ងៃមិនអាចកែប្រែឱ្យមកសភាពដើមវិញបាន ។ តែអ្នកស្រុកនៅតែនាំគ្នាព័ទ្ធចាប់បានហើយចងទុក ក្រែងមានសង្ឃឹមអាចព្យាបាលដូចដើម ។ បន្ទាប់មកអ្នកនោះឈឺលែងដឹងខ្លួនរហូតដល់បាត់បង់ជីវិត ។ នេះជាពត៌មានដែលយើងបានដឹងតាមរយៈអ្នកទាក់ដំរីនិងចាស់ទុំ ។



*ការប្រើប្រាស់ដំរីរបស់អ្នកស្រុកនៅតំបន់អង្គរ*

**ចប់**




# អ្នកស្រី កែវ ណារុំ

**ឆ្នាំ ២០០៤-២០០៥**

សញ្ញាបត្រកិត្តិយសជាវរសិល្បការិនី ផ្តល់ឱ្យដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ឯកទេស : តន្ត្រី និងស្រាវជ្រាវវប្បធម៌ខ្មែរ

**ឆ្នាំ ២០០៦**

វិញ្ញាបនបត្រអភិរក្សវប្បធម៌-សិល្បៈខ្មែរ ផ្តល់ឱ្យដោយរាជបណ្ឌិតសភាកម្ពុជាមានទេពកោសល្យផ្នែកស្រាវជ្រាវតន្ត្រីខ្មែរ